**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ......សហវ.-ប្រក

# ប្រកាស

## ស្តីពី

## វិធាននិងនីតិវិធីសម្រាប់បែងចែកចំណូលនិងចំណាយក្នុងចំណោមបុគ្គលជាប់ពន្ធ

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/៩០៣ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាព រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ៤ ខែ មេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាព រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹតលេខ ៤៨៨ ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
St.92,Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA. Phone : 855-23-724 664 Fax: 855-23-427 798

# សម្រេច

## ជំពូកទី១

### បទប្បញ្ញត្តិទូទៅ

**ប្រការ ១.- គោលបំណង**

ប្រកាសនេះ មានគោលបំណងដាក់ចេញនូវវិធាននិងនីតិវិធីសម្រាប់បែងចែកចំណូលនិងកំលោយក្នុងកិច្ចប្រតិបត្តិការអាជីវកម្មក្នុងចំណោមបុគ្គលទាក់ទិន។

**ប្រការ ២.- គោលដៅ**

ប្រកាសនេះមានគោលដៅកំណត់នូវថ្លៃសមស្របសម្រាប់ទំនិញ សេវា ឬទ្រព្យ កម្រិតចំណោញ និងកំណត់តម្រូវការឯកសារចាំបាច់នានាសម្រាប់ប្រតិបត្តិការអាជីវកម្មក្នុងចំណោមបុគ្គលទាក់ទិន។

**ប្រការ ៣.- វិសាលភាព**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះរាល់ប្រតិបត្តិការអាជីវកម្មរវាងបុគ្គលទាក់ទិនពីរឬច្រើន ដែលក្នុងចំណោមបុគ្គលទាក់ទិនទាំងនោះ បុគ្គលទាក់ទិនមួយយ៉ាងតិចជាអ្នកជាប់ពន្ធនិវាសនជន។

**ប្រការ ៤.- និយមន័យ**

សម្រាប់គោលដៅនៃប្រកាសនេះ ÷

១- ពាក្យ "បុគ្គលទាក់ទិន (Related Party)" សំដៅដល់

ក- សមាជិកណាម្នាក់ក្នុងវង្សញាតិអ្នកជាប់ពន្ធ

ខ- សហគ្រាសដែលគ្រប់គ្រងដោយអ្នកជាប់ពន្ធ ឬសហគ្រាសត្រូវបានអ្នកជាប់ពន្ធគ្រប់គ្រង ឬក៏សហគ្រាសនោះនិងអ្នកជាប់ពន្ធស្ថិតនៅក្រោមការគ្រប់គ្រងរួមគ្នា។ ពាក្យ "គ្រប់គ្រង" មានន័យថា មានកម្មសិទ្ធិចាប់ពី ២០ភាគរយ ឡើងទៅលើតម្លៃនៃភាគកម្មនៅក្នុងដើមទុនផ្ទាល់របស់សហគ្រាស ឬសិទ្ធិបោះឆ្នោតក្នុងក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន។ ដើម្បីកំណត់ទំហំនៃការគ្រប់គ្រងរបស់អ្នកជាប់ពន្ធជារូបវន្តបុគ្គលណាម្នាក់ ត្រូវគិតបញ្ចូលទាំងអស់នូវកម្មសិទ្ធិលើភាគកម្មនៅក្នុងដើមទុនផ្ទាល់របស់រូបវន្តបុគ្គលនោះ និងកម្មសិទ្ធិផ្ទាល់ ឬប្រយោលរបស់សហព័ទ្ធអ្នកជាប់ពន្ធ។

២- ពាក្យ "សហគ្រាសសម្ព័ន្ធញាតិ" សំដៅដល់ក្រុមសហគ្រាសដែលជាបុគ្គលទាក់ទិនស្របតាមលក្ខខណ្ឌដូចមានចែងក្នុងវាក្យខណ្ឌ ក និងវាក្យខណ្ឌ ខ នៃកថាខណ្ឌ ១ នៃប្រការនេះ។

៣- ពាក្យ "ថ្លៃផ្ទេរ (Transfer Price)" សំដៅដល់ថ្លៃរបស់ទំនិញ សេវា ឬទ្រព្យដែលបានផ្គត់ផ្គង់ក្នុងចំណោមបុគ្គលទាក់ទិន។

៤- ពាក្យ "ប្រតិបត្តិការមានការរៀបចំ (Controlled Transaction)" សំដៅដល់ប្រតិបត្តិការក្នុងចំណោមបុគ្គលទាក់ទិនដែលជាទូទៅតែងតែមានការរៀបចំទុកជាមុន។ សម្រាប់គោលដៅនៃប្រកាសនេះ រាល់ប្រតិបត្តិការជាមួយនឹងភាគីដែលបង្កើតឡើងនៅក្នុងប្រទេសដែលមានដែនយុត្តាធិការពន្ធទាបជាងព្រះរាជាណាចក្រកម្ពុជាត្រូវបានចាត់ទុកថាជាប្រតិបត្តិការមានការរៀបចំ។

៥- ពាក្យ "ប្រតិបត្តិការគ្មានការរៀបចំ (Uncontrolled Transaction)" សំដៅដល់ប្រតិបត្តិការដែលមិនមែនជាប្រតិបត្តិការមានការរៀបចំ និងដែលបានធ្វើឡើងដោយសហគ្រាសឯករាជ្យ។ សម្រាប់គោលដៅនៃប្រកាសនេះ ពាក្យ "សហគ្រាសឯករាជ្យ" សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមិនមែនជាបុគ្គលទាក់ទិន។

៦- ពាក្យ "គោលការណ៍ជំហោងដៃ (Arm's Length Principle)" សំដៅដល់គោលការណ៍សម្រាប់កំណត់ថ្លៃនៃប្រតិបត្តិការដែលមានលក្ខខណ្ឌដូចគ្នា ឬស្រដៀងគ្នា ដែលធ្វើឡើងក្នុងចំណោមសហគ្រាសឯករាជ្យ ដើម្បីប្រៀបធៀបនឹងថ្លៃនៃប្រតិបត្តិការណាមួយដែលបានធ្វើឡើងក្នុងចំណោមបុគ្គលទាក់ទិន។ សម្រាប់គោលដៅនៃប្រកាសនេះ ថ្លៃដែលបានកំណត់ក្រោមគោលការណ៍ជំហោងដៃ ហៅថា "ថ្លៃជំហោងដៃ (Arm's Length Price)"។

៧- ពាក្យ "ចំណូលដុល (Gross Incomes/Sales)" សំដៅដល់ចំណូលសរុបដែលបានមកពីសកម្មភាពអាជីវកម្មដោយពុំទាន់ដកអប្បហារ ការបង្វែរទំនិញត្រលប់មកវិញ ថ្លៃដើម និងចំណាយប្រតិបត្តិការ។

៨- ពាក្យ "កម្រិតចំណេញដុល (Gross Margin)" សំដៅដល់ផលធៀបរវាងចំណូលដុលក្រោយដកថ្លៃដើមនៃការផ្គត់ផ្គង់ទំនិញ សេវា ឬទ្រព្យ និងចំណូលដុលនៃការផ្គត់ផ្គង់ទំនិញ សេវា ឬទ្រព្យ ទាំងនោះ។

៩- ពាក្យ "ចំណូលដុលក្រោយដកថ្លៃដើម (Gross Profit)" សំដៅដល់ផលដករវាងចំណូលដុល និងថ្លៃដើម។

១០- ពាក្យ "កម្រិតចំណេញសុទ្ធ (Net Margin)" សំដៅដល់ផលធៀបរវាងចំណូលសុទ្ធ (ចំណូលដុលក្រោយដកថ្លៃដើមនិងក្រោយដកចំណាយប្រតិបត្តិការនៃការផ្គត់ផ្គង់ទំនិញ សេវា ឬទ្រព្យ) និងចំណូលដុលនៃការផ្គត់ផ្គង់ទំនិញ សេវា ឬទ្រព្យទាំងនោះ។

១១- ពាក្យ "កម្រិតចំណេញលើថ្លៃដើម (Mark-Up)" សំដៅដល់ផលធៀបរវាងចំណូលដុលក្រោយដកថ្លៃដើម និងថ្លៃដើម។

១២- ពាក្យ "ចំណេញនៅសល់ (Residual Profit)" សំដៅដល់ចំណេញដែលនៅសល់បន្ទាប់ពីការញែកចេញនូវចំណេញមូលដ្ឋានដែលជាចំណេញបានមកពីការផលិតឬចែកចាយទំនិញ ឬការផ្គត់ផ្គង់សេវា ដោយមិនគិតបញ្ចូលនូវចំណេញដែលទាក់ទិននឹងទ្រព្យអរូបិយផ្សេងៗ។

## ជំពូកទី២

## គោលការណ៍ទូទៅ

### ប្រការ ៥.- និដ្ឋភាពទូទៅនៃការផ្ទេរថ្លៃ

ការផ្ទេរថ្លៃកើតមានឡើងលើរាល់ប្រតិបត្តិការក្នុងចំណោមបុគ្គលទាក់ទិន។ ប្រតិបត្តិការការផ្ទេរថ្លៃអាចបង្វែរអត្ថប្រយោជន៍ផ្សេងៗពីបុគ្គលទាក់ទិនមួយទៅបុគ្គលទាក់ទិនដទៃទៀត តាមរយៈការបង្កើនឬបន្ថយថ្លៃទំនិញ សេវា ឬទ្រព្យ ដែលបានផ្គត់ផ្គង់ ហើយដែលថ្លៃទំនិញ សេវា ឬទ្រព្យទាំងនោះមិនបានឆ្លុះបញ្ចាំងពីចរន្តតម្លៃទីផ្សារជាក់ស្តែងដូចប្រតិបត្តិការអាជីវកម្មក្នុងចំណោមសហគ្រាសឯករាជ្យទេ។ ដូចនេះដើម្បីធានានូវភាពសមស្របនៃការផ្ទេរថ្លៃក្នុងចំណោមបុគ្គលទាក់ទិន គោលនយោបាយ វិធីសាស្ត្រ និងឯកសារគាំទ្រក្នុងការអនុវត្តការផ្ទេរថ្លៃ ត្រូវបានប្រើប្រាស់ និងប្រកាសដោយស្មោះត្រង់ត្រឹមត្រូវពីអ្នកជាប់ពន្ធ។

**ប្រការ ៦.- មុខងារ លក្ខខណ្ឌ**

១- ដើម្បីបែងចែកចំណូលចំណាយឱ្យបានសមស្របតាមគោលការណ៍ជំហោងដៃ បុព្វលក្ខខណ្ឌចាំបាច់តម្រូវឱ្យមានការវិភាគលើភាពដែលអាចធៀបបាន ដោយធ្វើការប្រៀបធៀបប្រតិបត្តិការមានការរៀបចំជាមួយនឹងប្រតិបត្តិការគ្មានការរៀបចំ។ ការប្រៀបធៀបនេះអាចអនុវត្តបាន ប្រសិនបើលក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌទាំងពីរខាងក្រោមត្រូវបានបំពេញ÷

ក- ប្រតិបត្តិការ ឬសហគ្រាសដែលបានធ្វើប្រតិបត្តិការ ដែលជាកម្មវត្ថុនៃការប្រៀបធៀប ពុំមានភាពខុសគ្នាដែលធ្វើឱ្យប៉ះពាល់ជាសារវន្តលើថ្លៃទីផ្សារ ឬ

ខ- ការធ្វើនិយ័តកម្មត្រឹមត្រូវសមហេតុផល អាចត្រូវបានធ្វើឡើងដើម្បីលុបបំបាត់ផលប៉ះពាល់ជាសារវន្តនៃភាពខុសគ្នាទាំងនោះ។

២- ការវិភាគលើភាពដែលអាចធៀបបាន ត្រូវផ្ដោតជាសំខាន់លើទំនាក់ទំនងពាណិជ្ជកម្មនិងហិរញ្ញវត្ថុក្នុងចំណោមបុគ្គលទាក់ទិន សកម្មភាពសេដ្ឋកិច្ច និងកត្តាផ្សេងៗ ដែលជះឥទ្ធិពលដល់សកម្មភាពសេដ្ឋកិច្ច រួមទាំងប្រតិបត្តិការដែលពាក់ព័ន្ធនឹងផលិតផលសាំញ៉ាំ ឬផលិតផលដែលមានបច្ចេកវិទ្យាខ្ពស់ ដូចជា សហ្វវែរកុំព្យូទ័រ ឬពាក់ព័ន្ធនឹងការប្រើប្រាស់សេវាដូចជា ការពិគ្រោះយោបល់ ឬវិស្វកម្ម ជាដើម។

**ប្រការ ៧.- កត្តាកំណត់ភាពដែលអាចធៀបបាន**

ក្រោមគោលការណ៍ជំហោងដៃ ដើម្បីកំណត់ភាពដែលអាចធៀបបាន ត្រូវធ្វើការប្រៀបធៀបលក្ខខណ្ឌរវាងប្រតិបត្តិការមានការរៀបចំ និងប្រតិបត្តិការរបស់សហគ្រាសឯករាជ្យ។ ការប្រៀបធៀបចរិតលក្ខណៈដែលពាក់ព័ន្ធនឹងស្ថានភាពសេដ្ឋកិច្ច ត្រូវតែធ្វើឡើងយ៉ាងល្អិតល្អន់ដោយផ្អែកលើភាពប្រហាក់ប្រហែលឬដូច តាមរយៈកត្តាមួយចំនួនដូចខាងក្រោម÷

១- លក្ខខណ្ឌកិច្ចសន្យានៃប្រតិបត្តិការ ជាអាទិ៍មាន÷

ក- ការបែងចែកការទទួលខុសត្រូវ ហានិភ័យ និងអត្ថប្រយោជន៍ដែលបានកំណត់នៅក្នុងកិច្ចសន្យា

ខ- លក្ខខណ្ឌដែលជះឥទ្ធិពលទៅលើថ្លៃឬកម្រិតចំណេញដូចជា លក្ខខណ្ឌឥណទាន លក្ខខណ្ឌទូទាត់ បរិមាណនៃការផ្គត់ផ្គង់ លក្ខខណ្ឌនៃការធានា ជាដើម

គ- ឥរិយាបថនៃការអនុវត្តកិច្ចសន្យារបស់បុគ្គលទាក់ទិនធៀបទៅនឹងការអនុវត្តរបស់សហគ្រាសឯករាជ្យ។ ក្នុងករណីដែលការអនុវត្តរបស់ភាគីពាក់ព័ន្ធខុសពីលក្ខខណ្ឌដែលមានចែងនៅក្នុងកិច្ចសន្យា ការអនុវត្តជាក់ស្ដែងត្រូវបានកំណត់ជាលក្ខខណ្ឌជំនួស។

២- ការវិភាគមុខងារបំពេញដោយភាគីនីមួយៗ ដើម្បីកំណត់នូវកម្រិតដែលអាចធៀបបាននៃប្រតិបត្តិការតាមរយៈការប្រៀបធៀប÷

ក- មុខងារតាមផ្នែកនីមួយៗ ជាអាទិ៍មាន ផ្នែកផលិត ផ្នែកទីផ្សារ ផ្នែកផ្សព្វផ្សាយ ផ្នែកស្រាវជ្រាវនិងអភិវឌ្ឍ ផ្នែករចនាផលិតផល...

ខ- ទ្រព្យសកម្មដែលដាក់ឱ្យប្រើប្រាស់ (អគាររោងចក្រ យន្តបរិក្ខារ...) ចរិតនៃទ្រព្យសកម្ម (អាយុកាល តម្លៃទីផ្សារ...) និងការប្រើប្រាស់ទ្រព្យអរូបី និង

គ- ហានិភ័យរបស់បុគ្គលទាក់ទិននីមួយៗ ជាអាទិ៍មាន ហានិភ័យទីផ្សារ ហានិភ័យហិរញ្ញវត្ថុរួមទាំងហានិភ័យអត្រាប្តូរប្រាក់ ហានិភ័យទាក់ទិននឹងជោគជ័យឬបរាជ័យនៃការស្រាវជ្រាវនិងអភិវឌ្ឍ...។ ដើម្បីកំណត់ពី ហានិភ័យក្នុងចំណោមបុគ្គលទាក់ទិន ត្រូវពិនិត្យលើហានិភ័យសំខាន់ៗដែលបានបែងចែកក្នុងកិច្ចសន្យាដូចជា អ្នកទទួលរងនូវហានិភ័យ អ្នកគ្រប់គ្រងហានិភ័យ និងអ្នកមានលទ្ធភាពហិរញ្ញវត្ថុក្នុងការប្រឈមជាមួយហានិភ័យ។

៣- លក្ខណៈនៃទ្រព្យ ឬសេវា តាមរយៈការប្រៀបធៀប៖

ក- ផលិតផល៖ ទ្រង់ទ្រាយ គុណភាព បរិមាណ...

ខ- សេវា៖ ចរិតនិងទំហំនៃការផ្គត់ផ្គង់... និង

គ- ទ្រព្យអរូបី៖ ទម្រង់នៃប្រតិបត្តិការ ប្រភេទទ្រព្យអរូបី... ។

៤- ស្ថានភាពសេដ្ឋកិច្ច តាមរយៈការប្រៀបធៀប៖

ក- ទីតាំងភូមិសាស្ត្រទីផ្សារ

ខ- ទំហំទីផ្សារ

គ- ទំនិញនិងសេវាដែលអាចជំនួសគ្នាបាន

ឃ- អន្តរាគមន៍សេដ្ឋកិច្ចរបស់រដ្ឋាភិបាល (ការកំហិតលើថ្លៃ និងពេលវេលានៃប្រតិបត្តិការ...)។

៥- យុទ្ធសាស្ត្រអាជីវកម្ម ជាអាទិ៍មាន៖

ក- នវានុវត្តន៍ (Innovation) និងការអភិវឌ្ឍផលិតផលថ្មី

ខ- កម្រិតនៃពិពិធកម្ម (Diversification)

គ- យុទ្ធសាស្ត្រវាយលុក ពង្រីក និងរក្សាទីផ្សារ

ឃ- បណ្តាញចែកចាយ

ង- ទំហំនិងទីតាំងទីផ្សារ...។

**ប្រការ ៨.- រង្វង់ជិះហោងដៃ**

រង្វង់ជិះហោងដៃ (Arm's Length Range) គឺជារង្វង់នៃតួលេខសូចនាករហិរញ្ញវត្ថុពាក់ព័ន្ធ (ឧ. ថ្លៃ ឬកម្រិតចំណេញ) ដែលទទួលបានពីការអនុវត្តវិធីសាស្ត្រផ្ទេរថ្លៃដូចមានចែងក្នុងប្រការ ៩ ដល់ប្រការ ១៤ នៃប្រកាសនេះ ដែលបានមកពីប្រតិបត្តិការគ្មានការរៀបចំអាចធៀបបានទៅនឹងប្រតិបត្តិការមានការរៀបចំ ដោយផ្អែកទៅលើការវិភាគលើភាពដែលអាចធៀបបាន ដូចមានចែងនៅក្នុងប្រការ ៧ នៃប្រកាសនេះ។

ប្រតិបត្តិការមានការរៀបចំនឹងមិនត្រូវបានធ្វើនិយ័តកម្មទេ ប្រសិនបើសូចនាករហិរញ្ញវត្ថុពាក់ព័ន្ធដែលបានមកពីប្រតិបត្តិការមានការរៀបចំ ត្រូវបានធ្វើតេស្តតាមវិធីសាស្ត្រផ្ទេរថ្លៃត្រឹមត្រូវ ដែលស្ថិតនៅក្នុងរង្វង់ជិះហោងដៃ។ ផ្ទុយទៅវិញ សូចនាករហិរញ្ញវត្ថុនៅក្នុងប្រតិបត្តិការមានការរៀបចំដែលស្ថិតនៅក្រៅរង្វង់ជិះហោងដៃ នឹងត្រូវធ្វើនិយ័តកម្មតាមមេដ្យានរបស់រង្វង់ជិះហោងដៃ។

## ជំពូកទី៣

## វិធីសាស្ត្រសម្រាប់បែងចែកចំណូលចំណាយក្នុងចំណោមបុគ្គលទាក់ទិន

**ប្រការ ៩.- វិធីសាស្ត្រសម្រាប់បែងចែកចំណូលចំណាយក្រោមគោលការណ៍ជំហានដៃ**

អនុលោមតាមមាត្រា ១៨ នៃច្បាប់ស្តីពីសារពើពន្ធ ដើម្បីបែងចែកចំណូលចំណាយក្នុងចំណោមបុគ្គលទាក់ទិនក្រោមគោលការណ៍ជំហានដៃ អ្នកជាប់ពន្ធអាចប្រើប្រាស់វិធីមួយឬច្រើនដូចខាងក្រោម÷

ក- វិធីថ្លៃគ្មានការរៀបចំអាចធៀបបាន- ថគធ (Comparable Uncontrolled Price-CUP)

ខ- វិធីថ្លៃផ្គត់ផ្គង់បន្ត- ថផប (Resale Price Method-RPM)

គ- វិធីបន្ថែមលើថ្លៃដើម- បថដ (Cost Plus Method-CPM)

ឃ- វិធីកម្រិតចំណេញសុទ្ធនៃប្រតិបត្តិការ- កចស (Transactional Net Margin Method-TNMM)

ង- វិធីញែកចំណេញ- ញច (Profit Split Method-PS)

អ្នកជាប់ពន្ធត្រូវបានតម្រូវឱ្យរៀបចំ និងផ្តល់ភស្តុតាងនិងឯកសារគាំទ្រសម្រាប់វិធីដែលបានជ្រើសរើសយកមកប្រើ។ ក្នុងករណីចាំបាច់ រដ្ឋបាលសារពើពន្ធមានសិទ្ធិណែនាំនិងកំណត់ឱ្យអ្នកជាប់ពន្ធប្រើប្រាស់វិធីណាមួយដែលសមស្របនឹងស្ថានភាពជាក់ស្តែងរបស់អ្នកជាប់ពន្ធ។

**ប្រការ ១០.- វិធីថ្លៃគ្មានការរៀបចំអាចធៀបបាន (ថគធ)**

១- វិធី ថគធ. គឺជាការប្រៀបធៀបរវាងថ្លៃដែលត្រូវបានកំណត់លើការផ្ទេរទំនិញ សេវា ឬទ្រព្យ នៅក្នុងប្រតិបត្តិការមានការរៀបចំ ទៅនឹងថ្លៃដែលត្រូវបានកំណត់លើការផ្ទេរទំនិញ សេវា ឬទ្រព្យ នៅក្នុងប្រតិបត្តិការគ្មានការរៀបចំនៅក្នុងកាលៈទេសៈប្រហាក់ប្រហែលគ្នា។ វិធីនេះសមស្របនៅក្នុងស្ថានភាពដែលទំនិញ សេវា ឬទ្រព្យ អាចប្រៀបធៀបគ្នាបាន ឬក្នុងស្ថានភាពដែលការធ្វើនិយ័តកម្មសមហេតុផលអាចត្រូវបានធ្វើឡើងដើម្បីបញ្ជាក់ថាថ្លៃទំនិញ សេវា ឬទ្រព្យទាំងនោះ មានឬគ្មានភាពសមស្រប។ ក្នុងករណី ទំនិញ សេវា ឬទ្រព្យ មានភាពខុសគ្នាជាសារវ័ន្តដែលនាំឱ្យមិនអាចធ្វើនិយ័តកម្មបាន ឬមិនអាចផ្តល់នូវការវាស់វែងសមស្របសម្រាប់ការកំណត់ថ្លៃជំហានដៃ វិធីផ្សេងទៀតអាចត្រូវបានយកមកប្រើប្រាស់។

២- ការវិភាគលើភាពដែលអាចធៀបបាន (Comparability Analysis)

ក. ដើម្បីធ្វើការកំណត់ថ្លៃផ្ទេរ សហគ្រាសដែលប្រើប្រាស់វិធី ថគធ. ជាដំបូងត្រូវកំណត់ឱ្យឃើញភាពខុសគ្នារវាងទំនិញឬសេវារបស់ខ្លួន ទៅនឹងទំនិញឬសេវារបស់សហគ្រាសឯករាជ្យ ហើយបន្ទាប់មកទៀតត្រូវកំណត់នូវភាពខុសគ្នាដែលមានផលប៉ះពាល់ជាសារវ័ន្តទៅលើថ្លៃ។ ប្រសិនបើមានភាពខុសគ្នាជាសារវ័ន្ត ត្រូវធ្វើនិយ័តកម្មឱ្យបានសមស្របទៅតាមថ្លៃទំនិញឬសេវា ដែលបានផ្គត់ផ្គង់ដោយសហគ្រាសឯករាជ្យ។

ខ. ក្នុងការវិភាគលើភាពដែលអាចធៀបបាន នៅក្រោមវិធី ថគធ. ត្រូវពិចារណាលើកត្តាមួយចំនួន ដូចខាងក្រោម÷

- លក្ខណៈទំនិញ ដូចជាទ្រង់ទ្រាយ និងគុណភាព
- ចរិត និងទំហំនៃសេវាដែលបានផ្គត់ផ្គង់

- ទំនិញដែលបានផ្គត់ផ្គង់ត្រូវបានប្រៀបធៀបនៅត្រង់ចំណុចដូចគ្នានៃខ្សែចង្វាក់ផលិតកម្ម
- លក្ខណៈដោយឡែករបស់ផលិតផលក្រោមទម្រង់ជាទ្រព្យអរូបី ដូចជាម៉ាកពាណិជ្ជកម្ម គំនូរប្លង់ ជាដើម។ល។
- ទំហំនៃការផ្គត់ផ្គង់ ប្រសិនបើមានផលប៉ះពាល់ទៅលើថ្លៃ
- ពេលវេលានៃការផ្គត់ផ្គង់ ប្រសិនបើមានផលប៉ះពាល់ទៅលើថ្លៃដោយសារការប្រែប្រួលនៃរដូវកាល ឬការផ្លាស់ប្តូរដទៃទៀតនៃលក្ខខណ្ឌទីផ្សារ
- ចំណាយលើការដឹកជញ្ជូន ការវេចខ្ចប់ ការស្វែងរកទីផ្សារ ការផ្សាយពាណិជ្ជកម្ម និងការធានា ប្រសិនបើចំណាយទាំងនោះត្រូវបានដាក់បញ្ចូលទៅក្នុងកិច្ចសន្យា
- ទីកន្លែងផ្គត់ផ្គង់ទំនិញ ឬសេវាមានលក្ខខណ្ឌសេដ្ឋកិច្ចដូច ឬប្រហាក់ប្រហែលគ្នា
- កត្តាផ្សេងទៀតដែលប៉ះពាល់លើថ្លៃ។

**ឧទាហរណ៍ទី ១ ៖**

សហគ្រាស ក ជាសហគ្រាសដែលផ្គត់ផ្គង់ទំនិញ៧០% ទៅឱ្យបុគ្គលទាក់ទិននៅក្រៅប្រទេស (សហគ្រាស ខ) ក្នុងតម្លៃ ១០០ ០០០៛ ក្នុងមួយឯកតា។ ទន្ទឹមនឹងនោះ ទំនិញ៣០%ទៀត ត្រូវបានផ្គត់ផ្គង់ទៅឱ្យសហគ្រាសឯករាជ្យក្នុងស្រុក (សហគ្រាស គ) ក្នុងតម្លៃ ១៥០ ០០០៛ ក្នុងមួយឯកតា។




សន្មតថា សហគ្រាស ក បានផ្គត់ផ្គង់ទៅឱ្យសហគ្រាស ខ និង សហគ្រាស គ នូវទំនិញដូចគ្នា។ ប្រតិបត្តិការរវាងសហគ្រាស ក និងសហគ្រាស គ អាចត្រូវបានចាត់ទុកជាមូលដ្ឋានប្រៀបធៀបផ្ទៃក្នុងសម្រាប់យកមកប្រើប្រាស់ជាប្រតិបត្តិការគ្មានការរៀបចំអាចធៀបបាន។ ប៉ុន្តែជាដំបូង ការវិភាគមុខងារទៅលើសហគ្រាស ក សហគ្រាស ខ និង សហគ្រាស គ ត្រូវតែធ្វើឡើង ដើម្បីរកឱ្យឃើញនូវភាពខុសគ្នាណាមួយដែលអាចមានផលប៉ះពាល់ជាសារវន្តទៅលើថ្លៃទីផ្សារ។ ប្រសិនបើមានភាពខុសគ្នា ការធ្វើនិយ័តកម្មដែលត្រឹមត្រូវ និងសមហេតុផលត្រូវបានធ្វើឡើងដើម្បីលុបបំបាត់នូវភាពខុសគ្នាទាំងនោះ។ ក្នុងករណីដែលគ្មានភាពខុសគ្នាណាមួយដែលអាចប៉ះពាល់ជាសារវន្តទៅលើថ្លៃទីផ្សារនោះទេ វិធី ថតឯ. អាចត្រូវបានយកមកអនុវត្តដោយប្រើប្រាស់ប្រតិបត្តិការគ្មានការរៀបចំអាចធៀបបានផ្ទៃក្នុង សម្រាប់ការកំណត់ថ្លៃឯកតានៃទំនិញចំនួន ១៥០ ០០០៛ ដែលជាថ្លៃជំហរដៃ។

ដូចនេះ ថ្លៃផ្ទេរចំនួន ១០០ ០០០៛ គួរត្រូវបានជំនួសដោយ ថ្លៃជំហរដៃចំនួន ១៥០ ០០០៛។ ក្នុងករណីនេះ ចំណូលរបស់សហគ្រាស ក នឹងកើនឡើង បន្ទាប់ពីការទទួលស្គាល់ថ្លៃជំហរដៃដែលខ្ពស់ជាងថ្លៃផ្ទេរដែលបានប្រើប្រាស់ដំបូង។ ការកើនឡើងចំណូលរបស់សហគ្រាស ក នឹងនាំឱ្យមានការប្រែប្រួលនូវកម្រិតចំណេញ ដូចមានបង្ហាញក្នុងតារាងខាងក្រោម៖

| សហគ្រាស ក | | | |
|---|---|---|---|
| | មុននិយ័តកម្ម | និយ័តកម្ម | ក្រោយនិយ័តកម្ម |
| ចំណូលដុល | ១០០ ០០០ | ៥០ ០០០ | ១៥០ ០០០ |
| ថ្លៃដើម | (៧០ ០០០) | | (៧០ ០០០) |
| ចំណូលដុលក្រោយដកថ្លៃដើម | ៣០ ០០០ | | ៨០ ០០០ |
| ចំណាយប្រតិបត្តិការផ្សេងៗ | (២០ ០០០) | | (២០ ០០០) |
| ចំណូលសុទ្ធ | ១០ ០០០ | | ៦០ ០០០ |

សរុបមកវិញ បន្ទាប់ពីអនុវត្តគោលការណ៍ជំហោងដៃ សហគ្រាស ក ត្រូវធ្វើនិយ័តកម្មមូលដ្ឋានគិតពន្ធចំនួន ៥០ ០០០៛ (៦០ ០០០ - ១០ ០០០)។ ទឹកប្រាក់ ៥០ ០០០៛ នេះ នឹងត្រូវយកទៅធ្វើនិយ័តកម្មលើចំណូលជាប់ពន្ធ និងពន្ធអាករពាក់ព័ន្ធដទៃទៀតជាធរមាន។

ក្នុងករណីមានការបញ្ចុះថ្លៃតាមបរិមាណផ្គត់ផ្គង់ដោយហេតុថាបរិមាណនៃការផ្គត់ផ្គង់ទៅឱ្យសហគ្រាស ខ និងសហគ្រាស គ មិនដូចគ្នា សហគ្រាស ក ត្រូវធ្វើនិយ័តកម្មដូចដែលបានអនុវត្តជាទូទៅនៅក្នុងឧស្សាហកម្ម ដើម្បីកែតម្រូវលើការបញ្ចុះថ្លៃនោះ។ សន្មតថា សហគ្រាស ក ជាធម្មតាផ្តល់ការបញ្ចុះថ្លៃ ១០% សម្រាប់ការផ្គត់ផ្គង់ក្នុងបរិមាណលើសពី ៥០% នៃទំនិញរបស់ខ្លួន។ ដូចនេះ ថ្លៃ ១០០ ០០០៛ ក្នុងមួយឯកតា ដែលផ្គត់ផ្គង់ឱ្យសហគ្រាស ខ គួរត្រូវបានធ្វើនិយ័តកម្មដូចខាងក្រោម÷

| | |
|---|---|
| ថ្លៃទីផ្សារ | ១៥០ ០០០៛ |
| ដកៈ ការបញ្ចុះថ្លៃ ១០% | (១៥ ០០០៛) |
| ថ្លៃផ្ទេរ | ១៣៥ ០០០៛ |

ប៉ុន្តែ ថ្លៃផ្ទេរដែលសហគ្រាស ក ផ្គត់ផ្គង់ទៅឱ្យសហគ្រាស ខ គឺ ១០០ ០០០៛។ ហេតុនេះ ទោះបីជាភាពខុសគ្នាដែលមានផលប៉ះពាល់ជាសារវ័ន្តទៅលើថ្លៃទីផ្សារត្រូវបានធ្វើនិយ័តកម្មដោយជឿជាក់និងសមហេតុផលក៏ដោយ ការអនុវត្តវិធី ថតឯ. បង្ហាញថា ថ្លៃផ្ទេរ ១០០ ០០០៛ គឺនៅទាបជាងថ្លៃជំហោងដៃដែលបានធ្វើនិយ័តកម្ម ១៣៥ ០០០៛។ ដូចនេះ ថ្លៃផ្ទេរដែលសហគ្រាស ក ផ្គត់ផ្គង់ទៅឱ្យសហគ្រាស ខ ១០០ ០០០៛ គួរត្រូវបានជំនួសដោយថ្លៃជំហោងដៃ ១៣៥ ០០០៛។ ក្នុងករណីនេះ ចំណូលរបស់សហគ្រាស ក នឹងកើនឡើងបន្ទាប់ពីការទទួលស្គាល់នូវថ្លៃដែលត្រូវបានធ្វើនិយ័តកម្ម និងខ្ពស់ជាងថ្លៃផ្ទេរដែលបានប្រើប្រាស់ដំបូង។ ការកើនឡើងចំណូលរបស់សហគ្រាស ក នឹងនាំឱ្យមានការប្រែប្រួលនូវចំណូលសុទ្ធ ដូចមានបង្ហាញក្នុងតារាងខាងក្រោម÷

| សហគ្រាស ក | | | |
|---|---|---|---|
| | មុននិយ័តកម្ម | និយ័តកម្ម | ក្រោយនិយ័តកម្ម |
| ចំណូលដុល | ១០០ ០០០ | ៣៥ ០០០ | ១៣៥ ០០០ |
| ថ្លៃដើម | (៧០ ០០០) | | (៧០ ០០០) |
| ចំណូលដុលក្រោយដកថ្លៃដើម | ៣០ ០០០ | | ៦៥ ០០០ |
| ចំណាយប្រតិបត្តិការផ្សេងៗ | (២០ ០០០) | | (២០ ០០០) |
| ចំណូលសុទ្ធ | ១០ ០០០ | | ៤៥ ០០០ |

សរុបមកវិញ បន្ទាប់ពីអនុវត្តគោលការណ៍ជំហោងដៃ សហគ្រាស ឥ ត្រូវធ្វើនិយ័តកម្មមូលដ្ឋានគិតពន្ធចំនួន ៣៥ ០០០៛ (៤៥ ០០០ - ១០ ០០០)។ ទឹកប្រាក់ ៣៥ ០០០៛ នេះ នឹងត្រូវយកទៅធ្វើនិយ័តកម្មលើចំណូលជាប់ពន្ធ និងពន្ធអាករពាក់ព័ន្ធដទៃទៀតជាធរមាន។

**ប្រការ ១១.- វិធីថ្លៃផ្គត់ផ្គង់បន្ត (ថផប)**

១- វិធី ថផប. ជាការប្រៀបធៀបរវាងកម្រិតចំណេញដុលនៃការផ្គត់ផ្គង់បន្តនូវទំនិញក្នុងប្រតិបត្តិការមានការរៀបចំជាមួយនឹងកម្រិតចំណេញដុលក្នុងប្រតិបត្តិការគ្មានការរៀបចំអាចធៀបបាន។ ជាទូទៅ វិធី ថផប. ជាវិធីសមរម្យបំផុតសម្រាប់ប្រតិបត្តិការដែលទាក់ទិននឹងមុខងារផ្គត់ផ្គង់ឬមុខងារចែកចាយដែលពុំប្រឈមនឹងហានិភ័យខ្ពស់ ឬមិនពាក់ព័ន្ធទៅនឹងប្រតិបត្តិការផ្គត់ផ្គង់ទ្រព្យអរូបីឯកលក្ខណៈនិងមានតម្លៃខ្ពស់។ អត្ថប្រយោជន៍ជាចម្បងនៃវិធីនេះផ្អែក សំខាន់លើតម្លៃបន្ថែម ឬការបំប្លែងដែលអ្នកផ្គត់ផ្គង់បន្តបានធ្វើឡើងមុនពេលផ្គត់ផ្គង់បន្ត។ វិធីនេះពិបាកនឹងអនុវត្ត ប្រសិនបើទំនិញត្រូវបានឆ្លងកាត់ច្រើនដំណាក់កាលនិងមានគម្លាតពេលវែង (ក្នុងករណីស្ថានភាពទីផ្សារអាចមានការប្រែប្រួល) មុនពេលដែលទំនិញត្រូវបានផ្គត់ផ្គង់ ឬនៅពេលដែលអ្នកផ្គត់ផ្គង់បន្ត បានបន្ថែមជាដុំកំភួនឬបង្កើតទ្រព្យអរូបីភ្ជាប់ទៅនឹងទំនិញនោះ។

$$\text{ថ្លៃជំហោងដៃ} = \text{ថ្លៃផ្គត់ផ្គង់បន្ត} - (\text{ថ្លៃផ្គត់ផ្គង់បន្ត} \times \text{កម្រិតចំណេញដុល})$$

$$\text{ដែល÷ កម្រិតចំណេញដុល} = \frac{\text{តម្លៃផ្គត់ផ្គង់} - \text{តម្លៃទិញ}}{\text{តម្លៃផ្គត់ផ្គង់}} = \frac{\text{ចំណូលដុលក្រោយដកថ្លៃដើម}}{\text{តម្លៃផ្គត់ផ្គង់}}$$

* កម្រិតចំណេញដុលលើការផ្គត់ផ្គង់បន្ត ត្រូវតែប្រៀបធៀបទៅនឹងកម្រិតចំណេញដុលទទួលបានដោយសហឯករាជ្យអាចប្រៀបធៀបបាន និងមានមុខងារ ហានិភ័យ និងទ្រព្យប្រហាក់ប្រហែលគ្នា។

ចំណុចចាប់ផ្តើមនៃវិធី ថផប. ជាថ្លៃនៃទំនិញដែលអ្នកផ្គត់ផ្គង់បន្ត ទិញពីបុគ្គលទាក់ទិន ហើយផ្គត់ផ្គង់បន្តទៅឱ្យសហគ្រាសឯករាជ្យ។ ថ្លៃផ្គត់ផ្គង់បន្តនេះ អាចធ្វើឱ្យអ្នកផ្គត់ផ្គង់បន្តមានកម្រិតចំណេញដុលមួយ ដែលអាចទូទាត់ចំណាយថ្លៃផ្គត់ផ្គង់ និងចំណាយប្រតិបត្តិការ ព្រមទាំងមុខងារផ្សេងៗទៀត (ដោយគិតបញ្ចូលទាំងទ្រព្យសកម្មដែលប្រើប្រាស់ និងហានិភ័យប្រឈម) ដើម្បីទទួលបានចំណូលសុទ្ធសមរម្យ។ ថ្លៃជំហោងដៃនៃប្រតិបត្តិការរវាងបុគ្គលទាក់ទិន ត្រូវបានកំណត់ដោយយកថ្លៃផ្គត់ផ្គង់បន្តដកចំណូលដុលក្រោយដកថ្លៃដើម។ វិធីគណនាកម្រិតចំណេញដុលត្រូវបានបង្ហាញដូចខាងក្រោម ÷

ចំណុចសំខាន់នៃរូបមន្តខាងលើ ស្ថិតនៅលើកម្រិតចំណេញដុលនៃការផ្គត់ផ្គង់បន្ត។ កម្រិតចំណេញដុលនេះ បានមកពីការប្រៀបធៀបផ្ទៃក្នុង ដែលជាប្រតិបត្តិការរបស់អ្នកផ្គត់ផ្គង់បន្ត (ពាក់ព័ន្ធប្រតិបត្តិការមានការរៀបចំ) ទៅឱ្យសហគ្រាសឯករាជ្យ។ ក្នុងករណីដែលគ្មានប្រតិបត្តិការអាចធៀបបាន កម្រិតចំណេញដុលនៃការផ្គត់ផ្គង់បន្តអាចត្រូវបានកំណត់ពីការផ្គត់ផ្គង់ដោយអ្នកផ្គត់ផ្គង់បន្តផ្សេងទៀតក្នុងទីផ្សារដូចគ្នា។ កម្រិតចំណេញដុលនៃការផ្គត់ផ្គង់បន្តអាចប្រែប្រួលទៅតាមតម្លៃបន្ថែមដែលអ្នកផ្គត់ផ្គង់បន្តបានធ្វើឡើងមុននឹងផ្គត់ផ្គង់បន្តផលិតផល។

២- ការវិភាគលើភាពដែលអាចធៀបបាន

ដើម្បីវិភាគលើភាពដែលអាចធៀបបាន ត្រូវពិចារណាលើកត្តាមួយចំនួនដែលជះឥទ្ធិពលលើកម្រិតចំណេញដុលនៃការផ្គត់ផ្គង់បន្ត ជាអាទិ៍មាន÷

ក- មុខងារ ឬកម្រិតសកម្មភាពធ្វើឡើងដោយអ្នកផ្គត់ផ្គង់បន្ត និងហានិភ័យដែលមាន (អ្នកផ្គត់ផ្គង់បន្តគ្រាន់តែជាភ្នាក់ងារបញ្ជូនបន្ត ឬក៏ជាអ្នកចែកចាយដែលទទួលខុសត្រូវស្វែងរកទីផ្សារនិងផ្សព្វផ្សាយផលិតផល ដោយប្រឈមមុខនឹងហានិភ័យនៃការបាត់បង់ធនធានផ្ទាល់ខ្លួន)

ខ- ការប្រើប្រាស់ទ្រព្យសកម្មប្រហាក់ប្រហែល ទាំងក្នុងប្រតិបត្តិការមានការរៀបចំនិងប្រតិបត្តិការគ្មានការរៀបចំ

គ- ភាពប្រហាក់ប្រហែលគ្នានៃផលិតផលនៅតែមានភាពចាំបាច់នៅពេលដែលមានប្រតិបត្តិការទាក់ទិននឹងទ្រព្យអរូបីដែលមានឯកលក្ខណៈនិងមានតម្លៃខ្ពស់

ឃ- ភាពខុសគ្នាក្នុងការគ្រប់គ្រងអាជីវកម្មដែលអាចជះឥទ្ធិពលលើកម្រិតចំណេញ ប្រសិនបើអត្រាកម្រិតចំណេញផ្គត់ផ្គង់បន្តគឺជាអត្រាដែលប្រើប្រាស់ដោយសហគ្រាសឯករាជ្យក្នុងប្រតិបត្តិការអាចធៀបបាន

ង- ចន្លោះពេលពីការទិញដំបូងរហូតដល់ការផ្គត់ផ្គង់បន្តផលិតផល ប្រសិនបើមានរយៈពេលវែងដែលអាចបណ្តាលឱ្យទីផ្សារ អត្រាប្តូរប្រាក់ និងថ្លៃដើម... មានការប្រែប្រួល

ច- សិទ្ធផ្តាច់មុខឬមិនផ្តាច់មុខក្នុងការផ្គត់ផ្គង់បន្តនូវផលិតផល

ឆ- ភាពខុសគ្នានៅក្នុងការអនុវត្តគណនេយ្យ ដែលទាមទារឱ្យមានការធ្វើនិយ័តកម្ម ដើម្បីធានានូវភាពដូចគ្នានៃសមាសធាតុថ្លៃដើម ដែលយកទៅប្រើប្រាស់ដើម្បីគណនាកម្រិតចំណេញដុល ក្នុងប្រតិបត្តិការមានការរៀបចំ និងប្រតិបត្តិការគ្មានការរៀបចំ

ជ- កត្តាផ្សេងទៀត ដែលប៉ះពាល់លើកម្រិតចំណេញដុល។

**ឧទាហរណ៍ទី២ ÷**

- សហគ្រាស **ក** ជាសហគ្រាសពហុជាតិផលិតផលិតផលមានគុណភាពខ្ពស់ ដែលមានទីតាំងនៅបរទេស។
- សហគ្រាស **ខ** ជាសហគ្រាសបុត្រសម្ព័ន្ធនៅកម្ពុជានៃសហគ្រាសពហុជាតិ **ក**។
- សហគ្រាស **គ** ជាក្រុមហ៊ុនឯករាជ្យនៅកម្ពុជា។
- សហគ្រាស **ឃ** ជាអ្នកចែកចាយបន្តឯករាជ្យទៅឱ្យអតិថិជននៅក្នុងប្រទេសកម្ពុជា។
- សហគ្រាស **ខ** បានទិញផលិតផលដែលមានគុណភាពខ្ពស់ពីសហគ្រាស **ក** ក្នុងតម្លៃ ៧ ៦០០៛ ក្នុងមួយឯកតា។ ហើយផ្គត់ផ្គង់បន្តទៅសហគ្រាស **គ** ក្នុងតម្លៃ ៨ ០០០៛ ក្នុង ១ ឯកតា។
- សហគ្រាស **ឃ** បានផ្គត់ផ្គង់បន្តនូវផលិតផលដែលអាចធៀបគ្នាបានក្នុងកាលៈទេសៈប្រហាក់ប្រហែលគ្នា ទៅនឹងការផ្គត់ផ្គង់របស់សហគ្រាស **ខ** និងទទួលបានកម្រិតចំណេញដុល ១០ ភាគរយ។



ឧទាហរណ៍ទី ២ បានបង្ហាញនូវភាពខុសគ្នានៃផលិតផលនៅពេលធ្វើការប្រៀបធៀបរវាងប្រតិបត្តិការមានការរៀបចំនិងប្រតិបត្តិការគ្មានការរៀបចំ ប៉ុន្តែវាមិនប៉ះពាល់ជាសារវ័ន្តទៅលើការអនុវត្តវិធីខាងលើទេដោយសារចំណុចសំខាន់នៃការប្រៀបធៀបផ្តោតទៅលើកម្រិតចំណេញដុល។ សហគ្រាស ខ និង សហគ្រាស ឃ មានមុខងារជាអ្នកផ្គត់ផ្គង់បន្តក្នុងទីផ្សារតែមួយ និងស្ថិតនៅក្នុងដំណាក់កាលនៃខ្សែចង្វាក់តម្លៃដូចគ្នាដែលនាំឱ្យកម្រិតចំណេញដុលលើការផ្គត់ផ្គង់បន្ត ១០% របស់សហគ្រាស ឃ អាចត្រូវបានប្រើប្រាស់ជាមូលដ្ឋានក្នុងការកំណត់ថ្លៃក្រោមគោលការណ៍ជំហោងដៃចំពោះការទិញដំបូងរបស់សហគ្រាស ខ ពីសហគ្រាស ក។

ដូចនេះកម្រិតចំណេញដុលរបស់សហគ្រាស ខ ៥% [(៨ ០០០ - ៧ ៦០០)/ ៨ ០០០] ត្រូវបានកែតម្រូវទៅអត្រា ១០% ហើយនិយ័តកម្មនេះត្រូវធ្វើឡើងលើថ្លៃផ្ទេរ ៧ ៦០០៛ក្នុងមួយឯកតា។ ចំពោះសហគ្រាស ខ ដើម្បីទទួលបានកម្រិតចំណេញដុល ១០% ថ្លៃផ្ទេរត្រូវបន្ថយមកត្រឹម ៧ ២០០៛ ដោយអនុវត្តថ្លៃជំហោងដៃតាមរូបមន្តដូចខាងក្រោម÷

| | |
|---|---|
| ថ្លៃជំហោងដៃនៃផលិតផលបានទិញ | = ៨ ០០០ - (៨ ០០០ x ១០%) = ៧ ២០០៛ |

តាមការគណនាខាងលើ ថ្លៃផ្ទេរដំបូងរបស់សហគ្រាស ខ ៧ ៦០០៛ ដែលមានកម្រិតចំណេញដុល ៥% ត្រូវបានថយមកនៅត្រឹម ៧ ២០០៛ ហើយមានកម្រិតចំណេញដុល ១០% ដូចសហគ្រាស ឃ ដែលជា សហគ្រាសឯករាជ្យដែរ។ ការថយចុះនៃថ្លៃដើម ធ្វើឱ្យប៉ះពាល់ដល់កម្រិតចំណេញដុលនៃសហគ្រាស ខ ដូចមានបង្ហាញក្នុងតារាងខាងក្រោម÷

| សហគ្រាស ខ | | | |
|---|---|---|---|
| | **មុននិយ័តកម្ម** | **និយ័តកម្ម** | **ក្រោយនិយ័តកម្ម** |
| ចំណូលដុល | ៨ ០០០ | | ៨ ០០០ |
| ថ្លៃដើម | (៧ ៦០០) | ៤០០ | (៧ ២០០) |
| ចំណូលដុលក្រោយដកថ្លៃដើម | ៤០០ | | ៨០០ |
| កម្រិតចំណេញដុល | ៤០០/៨០០០ = ៥% | | ៨០០/៨០០០=១០% |

សរុបមកវិញ បន្ទាប់ពីអនុវត្តគោលការណ៍ជំហោងដៃ សហគ្រាស ខ ត្រូវធ្វើនិយ័តកម្មមូលដ្ឋានគិតពន្ធចំនួន ៤០០៛ (៧ ៦០០ - ៧ ២០០)។ ទឹកប្រាក់ ៤០០៛ នឹងត្រូវយកទៅធ្វើនិយ័តកម្មលើចំណូលជាប់ពន្ធ និងពន្ធអាករពាក់ព័ន្ធដទៃទៀតជាធរមាន។

**ប្រការ ១២.- វិធីបន្ថែមលើថ្លៃដើម (បថដ)**

១- **វិធី បថដ.** គឺជាការប្រៀបធៀបកម្រិតចំណេញលើថ្លៃដើមដែលកើតឡើងដោយផ្ទាល់ និងដោយប្រយោលចំពោះការផ្គត់ផ្គង់ទំនិញ សេវា ឬទ្រព្យ នៅក្នុងប្រតិបត្តិការមានការរៀបចំ និងប្រតិបត្តិការគ្មានការរៀបចំ។

ជាទូទៅ វិធី **បថដ.** ត្រូវបានប្រើប្រាស់ក្នុងករណី÷

- ផលិតផលពាក់កណ្ដាលសម្រេចត្រូវបានផ្គត់ផ្គង់រវាងបុគ្គលទាក់ទិន

- នៅពេលសហគ្រាស បានសម្រេចចុះកិច្ចព្រមព្រៀងប្រើប្រាស់ទ្រព្យរួមគ្នា
- នៅពេលផលិតករ គឺជាផលិតករចុះកិច្ចសន្យា
- នៅពេលប្រតិបត្តិការមានការរៀបចំ គឺជាការផ្គត់ផ្គង់សេវា។

ដើម្បីគណនារកកម្រិតចំណេញលើថ្លៃដើម ត្រូវអនុវត្តតាមជំហានដូចខាងក្រោម÷

ក. ចំណុចចាប់ផ្តើមនៅក្នុងវិធី **បថដ.** គឺថ្លៃដើមរបស់អ្នកផ្គត់ផ្គង់។ ដើម្បីគណនារកថ្លៃដែលអ្នកផ្គត់ផ្គង់ទទួលបានពីអ្នកទិញ ត្រូវយកថ្លៃដើមបន្ថែមនូវកម្រិតចំណេញលើថ្លៃដើមដែលសមស្រប។ គោលការណ៍ជំហោងដៃ តម្រូវឱ្យធ្វើការប្រៀបធៀបកម្រិតចំណេញលើថ្លៃដើមនៃប្រតិបត្តិការមានការរៀបចំទៅនឹងកម្រិតចំណេញលើថ្លៃដើមនៃប្រតិបត្តិការគ្មានការរៀបចំដែលអាចធៀបបាន។ ដូចនេះ កម្រិតចំណេញលើថ្លៃដើមនៃប្រតិបត្តិការគ្មានការរៀបចំនឹងត្រូវបានយកមកប្រើប្រាស់ជាមូលដ្ឋានដើម្បីធ្វើនិយ័តកម្មកម្រិតចំណេញលើថ្លៃដើមនៃប្រតិបត្តិការមានការរៀបចំ។

| |
|---|
| រូបមន្តគណនាថ្លៃជំហោងដៃ÷ |
| ថ្លៃជំហោងដៃ = ថ្លៃដើម + (ថ្លៃដើម x កម្រិតចំណេញលើថ្លៃដើម) |
| ដែល÷ $\text{កម្រិតចំណេញលើថ្លៃដើម} = \frac{\text{ចំណូលដុល} - \text{ថ្លៃដើម}}{\text{ថ្លៃដើម}} = \frac{\text{ចំណូលដុលក្រោយដកថ្លៃដើម}}{\text{ថ្លៃដើម}}$ |

ខ. ដើម្បីធ្វើនិយ័តកម្មលើថ្លៃដើម ត្រូវពិចារណាលើធាតុផ្សំរបស់ថ្លៃដើមនោះ។ វិធីកំណត់ថ្លៃដើមនិងគោលនយោបាយគណនេយ្យត្រូវតែមានសង្គតិភាព និងអាចប្រៀបធៀបបានពីការិយបរិច្ឆេទមួយទៅការិយបរិច្ឆេទមួយទៀត រវាងប្រតិបត្តិការមានការរៀបចំ និងប្រតិបត្តិការគ្មានការរៀបចំ។ ថ្លៃដើមនៅក្នុងវិធី **បថដ.** គឺជាទឹកប្រាក់សរុបនៃថ្លៃដើមផ្ទាល់ និងថ្លៃដើមប្រយោលនៃផលិតកម្ម ឬការផ្គត់ផ្គង់។ ជាទូទៅបន្ទុកចំណាយហិរញ្ញវត្ថុមិនត្រូវបានគិតបញ្ចូលក្នុងមូលដ្ឋានថ្លៃដើមទេ។ ការបញ្ចូលចំណាយផ្សេងទៀតទៅក្នុងថ្លៃដើមត្រូវតែមានហេតុផលសមរម្យ ហើយអាចត្រូវបានយកមកពិចារណាតែក្នុងករណីដែលចំណាយទាំងនោះ ធ្វើឱ្យការប៉ាន់ស្មានកម្រិតចំណេញលើថ្លៃដើមកាន់តែសុក្រិត ដោយប្រៀបធៀបទៅនឹងចំណាយក្នុងថ្លៃដើមនៃប្រតិបត្តិការអាចធៀបបាន។

២- ការវិភាគលើភាពដែលអាចធៀបបាន

នៅពេលអនុវត្តនូវវិធី **បថដ.** ចាំបាច់ត្រូវមានការវិភាគលើភាពដែលអាចធៀបបាននៃមុខងារ ហានិភ័យ លក្ខខណ្ឌនៃកិច្ចសន្យា ស្ថានភាពទីផ្សារ និងយុទ្ធសាស្ត្រអាជីវកម្ម ព្រមទាំងនិយ័តកម្មផ្សេងៗដែលបានធ្វើ ដើម្បីលុបបំបាត់ផលប៉ះពាល់នៃភាពខុសគ្នាលើកត្តានានាដូចមានចែងក្នុងប្រការ ៧ នៃប្រកាសនេះ រវាងប្រតិបត្តិការមានការរៀបចំនិងប្រតិបត្តិការគ្មានការរៀបចំ ។ ដូចគ្នាទៅនឹងវិធី **ថផប.**ដែរ វិធី **បថដ.** មានការធ្វើនិយ័តកម្មលើភាពខុសគ្នានៃផលិតផលតិចជាង បើប្រៀបធៀបទៅនឹងវិធី **ថគធ.**។

**ឧទាហរណ៍ទី ៣ ៖**

សហគ្រាស គ ជាសហគ្រាសបុគ្គលសម្ព័ន្ធនៅក្នុងប្រទេសកម្ពុជានៃសហគ្រាស ក ដែលជាសហគ្រាសពហុជាតិនៅបរទេស។ សហគ្រាស គ ជាអ្នកផលិតសមាសភាគគ្រឿងអគ្គិសនីជាពិសេសតាមការតម្រូវរបស់សហគ្រាស ក។ សហគ្រាស គ ទិញវត្ថុធាតុដើមប្រើប្រាស់សម្រាប់ផលិតសមាសភាគគ្រឿងអគ្គិសនីពីសហគ្រាសឯករាជ្យ ឃ ក្នុងតម្លៃ ២ ០០០៛ ក្នុងមួយឯកតា។ ថ្លៃដើមសរុបនៃសមាសភាគដែលផ្គត់ផ្គង់ទៅឱ្យសហគ្រាស ក ក្នុងមួយឯកតាថ្លៃ ៨ ០០០៛។ សហគ្រាស គ ផ្គត់ផ្គង់សមាសភាគគ្រឿងអគ្គិសនីទៅឱ្យសហគ្រាស ក ក្នុងតម្លៃ **១០ ០០០ ៛** ក្នុងមួយឯកតា។




| **សហគ្រាស គ** | | |
|---|---|---|
| ចំណូលដុល | | ១០ ០០០ |
| ការទិញ | ២ ០០០ | |
| ចំណាយផលិតកម្ម | ៥ ០០០ | |
| ចំណាយផ្សេងៗក្នុងផលិតកម្ម | ១ ០០០ | |
| ថ្លៃដើមសរុប | | (៨ ០០០) |
| ចំណូលដុលក្រោយដកថ្លៃដើម | | ២ ០០០ |

តាមឧទាហរណ៍ខាងលើ ការកំណត់ថ្លៃសមាសភាគគ្រឿងអគ្គិសនីដោយវិធី **ថតឯ.** មិនអាចធ្វើបាន ព្រោះគ្មានប្រតិបត្តិការផ្ទៃក្នុងដែលអាចផ្ទៀបបាន (internal comparable transactions)។ សមាសភាគគ្រឿងអគ្គិសនីត្រូវបានផលិតទៅតាមការបញ្ជាទិញពិសេស ដែលនាំឱ្យលំបាកក្នុងការស្វែងរកព័ត៌មាននៃប្រតិបត្តិការអាចផ្ទៀបបានដើម្បីយកមកប្រើប្រាស់។ ដូចនេះ ត្រូវស្វែងរកទិន្នន័យពាណិជ្ជកម្ម (Commercial databases) របស់សហគ្រាសឯករាជ្យដែលមានប្រតិបត្តិការអាចផ្ទៀបបានក្នុងកាលៈទេសៈប្រហាក់ប្រហែលគ្នាយកមកប្រើប្រាស់។ ខាងក្រោមនេះគឺជាកម្រិតចំណេញបន្ថែមលើថ្លៃដើមដែលបានគណនាចេញពីព័ត៌មានហិរញ្ញវត្ថុរបស់សហគ្រាសដែលអាចប្រៀបផ្ទៀបបានចំនួន ៥៖

| សហគ្រាសដែលអាចប្រៀបផ្ទៀបបាន | កម្រិតចំណេញបន្ថែមលើថ្លៃដើម |
|---|---|
| សហគ្រាសទី ១ | ២៨% |
| សហគ្រាសទី ២ | ៣១% |
| សហគ្រាសទី ៣ | ៣៥% |
| សហគ្រាសទី ៤ | ៣៧% |
| សហគ្រាសទី ៥ | ៤០% |

ក្នុងករណីនេះ រង្វង់ជំហោងដៃ (ដូចបានបង្ហាញនៅក្នុងប្រការ ៨ នៃប្រកាសនេះ) នៃកម្រិតចំណេញបន្ថែមលើថ្លៃដើមប្រែប្រួលពី ចន្លោះ ២៨% ទៅ ៤០% ដែលនាំឱ្យមានមេដ្យាន ៣៥%។

សហគ្រាស ឥ មានកម្រិតចំណេញបន្ថែមលើថ្លៃដើម ២៥% (២ ០០០/៨ ០០០=២៥%)។ កម្រិតចំណេញបន្ថែមលើថ្លៃដើមអាចធៀបបានរបស់សហគ្រាសដែលមានមុខងារ ហានិភ័យ និងទ្រព្យសកម្មប្រហាក់ប្រហែលគ្នាអាចត្រូវបានយកមកប្រើប្រាស់ជាមូលដ្ឋានក្នុងការកំណត់ថ្លៃជំហោងដៃ។ ដោយសារកម្រិតចំណេញបន្ថែមលើថ្លៃដើមនៃថ្លៃជំហោងដៃស្មើនឹង ៣៥% ដូចនេះ ថ្លៃជំហោងដៃរបស់សមាសភាគគ្រឿងអគ្គិសនីដែលសហគ្រាស ឥ បានផ្គត់ផ្គង់ឱ្យសហគ្រាស ឥ ត្រូវបានកំណត់ដូចខាងក្រោម÷

| | |
|---|---|
| ថ្លៃជំហោងដៃនៃការលក់សមាសភាគអគ្គិសនី | =៨ ០០០+(៨ ០០០x ៣៥%)<br>=៨ ០០០+ ២ ៨០០= ១០ ៨០០៛ ជំនួសឱ្យ ១០ ០០០៛ |

សរុបមកវិញ ក្រោយពីបានអនុវត្តគោលការណ៍ថ្លៃជំហោងដៃ សហគ្រាស គ ត្រូវធ្វើនិយ័តកម្មទៅលើមូលដ្ឋានគិតពន្ធចំនួន ៨០០៛(១០ ៨០០- ១០ ០០០)។ ទឹកប្រាក់ចំនួន ៨០០៛ នឹងត្រូវយកទៅធ្វើនិយ័តកម្មលើចំណូលជាប់ពន្ធ និងពន្ធអាករពាក់ព័ន្ធដទៃទៀតជាធរមាន។

**ប្រការ ១៣.- វិធីកម្រិតចំណេញសុទ្ធនៃប្រតិបត្តិការ (កចស)**

វិធី **កចស.** មានលក្ខណៈស្រដៀងនឹងវិធី បថដ. និង វិធី ថផប. ដោយសារការប្រើប្រាស់គោលការណ៍កម្រិតចំណេញ។ វិធី **កចស.**តម្រូវឱ្យធ្វើការប្រៀបធៀបកម្រិតចំណេញសុទ្ធដែលសហគ្រាសសម្រេចបានក្នុងប្រតិបត្តិការមានការរៀបចំ នឹងកម្រិតចំណេញសុទ្ធដែលសហគ្រាសសម្រេចបានពីប្រតិបត្តិការគ្មានការរៀបចំដោយផ្អែកលើមូលដ្ឋានដូចគ្នា (ឧ. ថ្លៃដើម ទ្រព្យសកម្ម ការផ្គត់ផ្គង់)។ ការវិភាគលើភាពដែលអាចធៀបបាន (រួមទាំងការវិភាគមុខងារ) ដែលចាត់ទុកថាធ្វើឡើងបានសមស្រប ត្រូវផ្អែកលើព័ត៌មានដែលពាក់ព័ន្ធនឹងកត្តាកំណត់ភាពដែលអាចធៀបបានដូចមានចែងក្នុងប្រការ ៧ នៃប្រកាសនេះ ដែលប្រមូលបានពីភាគីពាក់ព័ន្ធនានាក្នុងប្រតិបត្តិការមានការរៀបចំ។

**ឧទាហរណ៍ទី ៤÷**

សហគ្រាស ឥ ជាសហគ្រាសបង្កើតនៅក្នុងព្រះរាជាណាចក្រកម្ពុជានិងជាបុត្រសម្ព័ន្ធនៃសហគ្រាស ខ ដែលមានទីតាំងនៅបរទេស។ សហគ្រាស ខ ផលិតកុំព្យូទ័រផ្គត់ផ្គង់ឱ្យសហគ្រាស ឥ និងផ្គត់ផ្គង់ឱ្យអ្នកចែកចាយជាបុគ្គលទាក់ទិននៅតាមប្រទេសនានា។ កុំព្យូទ័រដែលចែកចាយដោយសហគ្រាស ឥ មានម៉ាកពាណិជ្ជកម្ម (Trademark) ដែលជាកម្មសិទ្ធិរបស់សហគ្រាស ខ។ ក្រៅពីការផ្គត់ផ្គង់កុំព្យូទ័រ សហគ្រាស ឥ ក៏ផ្តល់ផងដែរនូវសេវាផ្នែកបច្ចេកទេសដល់អតិថិជន។




របាយការណ៍លទ្ធផលរបស់សហគ្រាស ក មានដូចខាងក្រោម÷

| បរិយាយ | ទឹកប្រាក់មុននិយ័តកម្ម |
|---|---|
| ចំណូលពីការផ្គត់ផ្គង់ | ១០០ ០០០ |
| ថ្លៃដើមទំនិញ | (៩០ ០០០) |
| ចំណូលដុលក្រោយដកថ្លៃដើម | ១០ ០០០ |
| ចំណាយប្រតិបត្តិការផ្សេងៗ | (១៥ ០០០) |
| ចំណូលសុទ្ធ | (៥ ០០០) |
| កម្រិតចំណេញសុទ្ធ | (៥%) |

សន្ទតថាវិធី ថគផ. ឬវិធី ថផប. មិនអាចយកមកអនុវត្តបានដោយមូលហេតុ (១) ពុំមានផលិតផលស្រដៀង ឬគ្មាននិយ័តកម្មដែលអាចជឿទុកចិត្តណាមួយអាចធ្វើឡើងបាន ដើម្បីកែតម្រូវភាពខុសគ្នារវាងផលិតផលទាំងនោះទេ (២) ពុំអាចវាស់វែងកម្រិតចំណេញដុលដែលអាចធៀបបាន ដោយសហគ្រាសឯករាជ្យនីមួយៗអនុវត្តវិធានគណនេយ្យខុសគ្នា។

ដូចនេះ គួរប្រើប្រាស់វិធី កចស. ដែលផ្អែកលើមូលដ្ឋានផលធៀបរវាងចំណូលសុទ្ធ និងចំណូលពីការផ្គត់ផ្គង់របស់សហគ្រាសឯករាជ្យដែលធ្វើប្រតិបត្តិការអាចធៀបបាន ក្រោមស្ថានភាពស្រដៀងគ្នានិងដែលអាចរកបាននៅក្នុងទិន្នន័យពាណិជ្ជកម្មឬព័ត៌មានដែលអាចជឿជាក់ពីប្រភពផ្សេងទៀត។

ខាងក្រោមគឺជាព័ត៌មានកម្រិតចំណេញសុទ្ធនៃប្រតិបត្តិការ ដែលបានគណនាចេញពីព័ត៌មានហិរញ្ញវត្ថុ របស់សហគ្រាសដែលអាចធៀបបានចំនួន ៤ ÷

| **សហគ្រាសដែលអាចធៀបបាន** | **កម្រិតចំណេញសុទ្ធនៃប្រតិបត្តិការ** |
|---|---|
| សហគ្រាសទី ១ | ៦% |
| សហគ្រាសទី ២ | ៧% |
| សហគ្រាសទី ៣ | ៩% |
| សហគ្រាសទី ៤ | ១០% |

ក្នុងករណីនេះ រង្វង់ជំហោងដៃ (ដូចមានចែងក្នុងប្រការ ៨ នៃប្រកាសនេះ) ប្រែប្រួលពីចន្លោះ ៦% ទៅ ១០% ដែលមានមេដ្យាន ៨% [(៧ + ៩) / ២] នៃកម្រិតចំណេញសុទ្ធ។

សហគ្រាស ក ទទួលបាននូវកម្រិតចំណេញសុទ្ធនៃប្រតិបត្តិការ -៥% ( -៥ ០០០ / ១០០ ០០០ = -៥%)។ កម្រិតចំណេញសុទ្ធនៃប្រតិបត្តិការរបស់សហគ្រាសឯករាជ្យអាចធៀបបានដែលមានមុខងារ ហានិភ័យ និងទ្រព្យសកម្មប្រហាក់ប្រហែលគ្នាអាចត្រូវបានប្រើប្រាស់ជាមូលដ្ឋានក្នុងការកំណត់ថ្លៃជំហោងដៃ។ ដោយសារកម្រិតចំណេញសុទ្ធនៃប្រតិបត្តិការក្រោមគោលការណ៍ជំហោងដៃស្មើនឹង ៨% ថ្លៃជំហោងដៃរបស់កុំព្យូទ័រដែលសហគ្រាស ខ បានផ្គត់ផ្គង់ឱ្យសហគ្រាស ក ត្រូវបានកំណត់ដូចខាងក្រោម÷

| | |
|---|---|
| ចំណូលសុទ្ធរបស់សហគ្រាស ក | = ១០០ ០០០ x ៨% = ៨ ០០០ |
| ថ្លៃដើមទំនិញក្រោយធ្វើនិយ័តកម្ម | = ១០០ ០០០ - ១៥ ០០០ - ៨ ០០០ = ៧៧ ០០០ |

| **សហគ្រាស ក** | | | |
|---|---|---|---|
| **បរិយាយ** | **មុននិយ័តកម្ម** | **និយ័តកម្ម** | **ក្រោយនិយ័តកម្ម** |
| ចំណូលពីការផ្គត់ផ្គង់ | ១០០ ០០០ | | ១០០ ០០០ |
| ថ្លៃដើមទំនិញបានផ្គត់ផ្គង់ | (៩០ ០០០) | ១៣ ០០០ | (៧៧ ០០០) |
| ចំណូលដុលក្រោយដកថ្លៃដើម | ១០ ០០០ | | ២៣ ០០០ |
| ចំណាយប្រតិបត្តិការផ្សេងៗ | (១៥ ០០០) | | (១៥ ០០០) |
| ចំណូលសុទ្ធ | (៥ ០០០) | | ៨ ០០០ |
| កម្រិតចំណេញសុទ្ធនៃប្រតិបត្តិការ | (៥%) | | ៨% |

សរុបមកវិញ ក្រោយពីបានអនុវត្តគោលការណ៍ថ្លៃជំហោងដៃ សហគ្រាស ក ត្រូវធ្វើនិយ័តកម្មទៅលើមូលដ្ឋានគិតពន្ធចំនួន ១៣ ០០០៛ (៩០ ០០០ - ៧៧ ០០០)។ ទឹកប្រាក់ចំនួន ១៣ ០០០ ៛ នឹងត្រូវយកទៅធ្វើនិយ័តកម្មលើចំណូលជាប់ពន្ធ និងពន្ធអាករពាក់ព័ន្ធដទៃទៀតជាធរមាន។

**ប្រការ ១៤.- វិធីបែងចែកចំណេញ (ពបច)**

វិធី ពបច. អាចត្រូវបានប្រើប្រាស់នៅពេលដែលគ្មានប្រតិបត្តិការអាចធៀបបានរបស់សហគ្រាសឯករាជ្យ។ វិធីនេះសមស្របបំផុត ក្នុងករណីដែលភាគីទាំងអស់មានប្រតិបត្តិការពាក់ព័ន្ធទៅនឹងការបង្កើតទ្រព្យអរូបីឯកលក្ខណៈនិងមានតម្លៃខ្ពស់ ព្រោះសហគ្រាសឯករាជ្យទាំងឡាយអាចមានបំណងបែងចែកចំណេញទៅតាមកម្រិតនៃការចូលរួមចំណែករបស់ភាគីនីមួយៗ។

វិធី ពបច. ត្រូវបានប្រើប្រាស់សម្រាប់បែងចែកចំណែកនៃចំណេញឬខាត ទៅឱ្យបុគ្គលទាក់ទិនដែលចូលរួមក្នុងប្រតិបត្តិការមានការរៀបចំ ទៅតាមកម្រិតចំណេញឬខាត ដែលសហគ្រាសឯករាជ្យរំពឹងថានឹងទទួលបានពីប្រតិបត្តិការគ្មានការរៀបចំអាចធៀបបាន។ នៅពេលដែលអាចកំណត់បាននូវលាភការតាមគោលការណ៍ជំហោងដៃសម្រាប់

មុខងារមួយចំនួនដែលធ្វើឡើងក្នុងប្រតិបត្តិការក្នុងចំណោមបុគ្គលទាក់ទិន វិធី ញ២. ត្រូវអនុវត្តដោយផ្អែកលើចំណេញនៅសល់ពីមុខងារដែលបានបំពេញ។

ការញែកចំណេញ (ប៉ាន់ស្មាន ឬជាក់ស្តែង) អាចត្រូវបានអនុវត្តតាមរបៀបញែកចំណេញដែលនៅសល់ (Residual Profit Split Approach) និងរបៀបវិភាគលើការរួមចំណែក (Contribution Analysis Approach)។

១- របៀបញែកចំណេញដែលនៅសល់ចែកចេញជា ២ ដំណាក់កាល។ ដំណាក់កាលដំបូង ត្រូវញែកចំណេញជាមូលដ្ឋានរបស់ភាគីនីមួយៗ។ ចំណេញជាមូលដ្ឋានទាំងនេះ ត្រូវបានបែងចែកទៅតាមមុខងារជាមូលដ្ឋានដែលភាគីនីមួយៗបានបំពេញ ដោយផ្អែកលើចំណេញជាមូលដ្ឋាននៃទីផ្សារ ដែលទទួលបានដោយសហគ្រាសឯករាជ្យ ពីប្រតិបត្តិការប្រហាក់ប្រហែលគ្នា។ ជាទូទៅ ការញែកចំណេញជាមូលដ្ឋាន អាចអនុវត្តបានដោយប្រើប្រាស់វិធីណាមួយក្នុងចំណោមវិធីដែលមានចែងក្នុងប្រការ ១០ ដល់ ប្រការ ១៣ នៃប្រកាសនេះ។ ចំណេញជាមូលដ្ឋានមិនរួមបញ្ចូលទេនូវចំណេញដែលទទួលបានពីទ្រព្យសកម្មឯកលក្ខណៈនិងមានតម្លៃខ្ពស់ ដែលកាន់កាប់ដោយភាគីចូលរួម។ ដំណាក់កាលបន្ទាប់ គឺជាការញែកចំណេញឬខាតដែលនៅសល់ក្រោយការញែកចំណេញជាមូលដ្ឋាន ដោយផ្អែកលើមូលដ្ឋាននៃការញែកដែលសហគ្រាសឯករាជ្យបានធ្វើឡើងនៅក្នុងស្ថានភាពប្រហាក់ប្រហែលគ្នា។

**ឧទាហរណ៍ទី ៥ ៖**

សហគ្រាស ក និងសហគ្រាស ខ ជាបុគ្គលទាក់ទិន។ សហគ្រាស គ ជាសហគ្រាសឯករាជ្យ។ សហគ្រាស ក រចនាគំរូនិងផលិតផលិតផលអគ្គីសនីឯកលក្ខណៈនិងមានតម្លៃខ្ពស់ហើយផ្គត់ផ្គង់ទៅឱ្យសហគ្រាស ខ។ សហគ្រាស ខ បានផ្គត់ផ្គង់ផលិតផលអគ្គីសនីនោះទៅឱ្យសហគ្រាស គ ដែលជាអ្នកចែកចាយបន្ត ក្រោមពាណិជ្ជសញ្ញា "**អង្គរ**" ដែលជាកម្មសិទ្ធ និង អភិវឌ្ឍដោយសហគ្រាស ខ។




របាយការណ៍លទ្ធផលរបស់សហគ្រាស ក និង សហគ្រាស ខ មានដូចខាងក្រោម៖

| **សហគ្រាស** | **ក** | **ខ** |
|---|---|---|
| ចំណូលពីការផ្គត់ផ្គង់ | ១០០ | ៣០០ |
| ការទិញ | (១៥) | (១០០) |
| ថ្លៃបំប្លែង | (២០) | (៣៥) |
| ចំណូលដុលក្រោយដកថ្លៃដើម | ៦៥ | ១៦៥ |
| ចំណាយស្រាវជ្រាវ និងអភិវឌ្ឍ/ចំណាយទីផ្សារ | (២០) | (១៥) |
| ចំណាយប្រតិបត្តិការផ្សេងៗ | (១៥) | (១០) |
| ចំណូលសុទ្ធ | ៣០ | ១៤០ |

តាមព័ត៌មានខាងក្រៅ មានសហគ្រាសឯករាជ្យមួយចំនួនមានមុខរបរស្រដៀងគ្នាទៅនឹងសហគ្រាស **ក** និង សហគ្រាស **ខ** ដែលទោះបីជាផលិតផលផលិតដោយសហគ្រាស **ក** មានលក្ខណៈទំនើបជាងផលិតផលរបស់គូប្រជែង និងពាណិជ្ជសញ្ញា "**អង្គរ**" ជាពាណិជ្ជសញ្ញាមួយមានតម្លៃថ្លៃជាងគេក្នុងទីផ្សារក៏ដោយ ប្រសិនបើគ្មានឥទ្ធិពលពីទ្រព្យអរូបីដែលមានតម្លៃខ្ពស់ កម្រិតចំណេញជាមធ្យមមាន ៣០% នៃចំណាយសរុបសម្រាប់ផលិតករឯករាជ្យ និង ៥% នៃការផ្គត់ផ្គង់ សម្រាប់អ្នកចែកចាយឯករាជ្យ។

**វិធីសាស្ត្រអនុវត្ត÷**

ដើម្បីអនុវត្តវិធី ញច. ត្រូវធ្វើការវិភាគលើចំណេញដែលនៅសល់។ សន្មតថា នៅដំណាក់កាលដំបូងនៃការវិភាគលើចំណេញដែលនៅសល់ គ្មានទិន្នន័យនិងព័ត៌មានគ្រប់គ្រាន់សម្រាប់អនុវត្តវិធី **បថដ.** ចំពោះសហគ្រាស **ក** និងវិធី **ថផប.** ចំពោះសហគ្រាស **ខ** ទេ។

**ក. ការបែងចែកចំណេញនៅសល់ចេញពីចំណេញសរុបរបស់សហគ្រាសសម្ព័ន្ធញាតិ**

ការគណនាចំណេញសរុប÷

| | |
|---|---|
| ចំណូលពីការផ្គត់ផ្គង់សរុប | ៣០០ |
| ថ្លៃដើមទំនិញរបស់សហគ្រាស **ក** | (៣៥) |
| ថ្លៃដើមទំនិញរបស់សហគ្រាស **ខ** (មិនរួមបញ្ចូលការទិញពីសហគ្រាសសម្ព័ន្ធញាតិ) | (៣៥) |
| ចំណូលដុលក្រោយដកថ្លៃដើម | ២៣០ |
| ការស្រាវជ្រាវ និងការអភិវឌ្ឍន៍/ចំណាយទីផ្សារ | (៣៥) |
| ចំណាយប្រតិបត្តិការផ្សេងៗ | (២៥) |
| ចំណូលសុទ្ធ | ១៧០ |

ការគណនាចំណេញមូលដ្ឋាន÷

កម្រិតចំណេញលើថ្លៃដើមទទួលបានពីប្រភពខាងក្រៅត្រូវបានប្រើប្រាស់ដើម្បីគណនាចំណេញមូលដ្ឋានសម្រាប់សហគ្រាស **ក** និង សហគ្រាស **ខ**។

| | |
|---|---|
| ចំណេញមូលដ្ឋានសម្រាប់សហគ្រាស **ក** | =៣០% x (ថ្លៃដើម+ចំណាយប្រតិបត្តិការផ្សេងៗ)<br>=៣០% (៣៥ + ១៥) = ១៥ |
| ការគណនាចំណេញមូលដ្ឋានសម្រាប់សហគ្រាស **ខ** | = ៥% x ៣០០= ១៥ |

**ខ. ការគណនាចំណេញនៅសល់**

| | |
|---|---|
| ចំណេញនៅសល់ | = ចំណេញសរុប - [(ចំណេញមូលដ្ឋានសម្រាប់សហគ្រាស **ក**) + (ចំណេញមូលដ្ឋានសម្រាប់សហគ្រាស **ខ**)] |
| | = ១៧០ - (១៥ + ១៥) = ១៤០ |

សន្មតថា ចំណាយលើការស្រាវជ្រាវនិងអភិវឌ្ឍ ចំណាយទីផ្សារ និងចំណាយផ្សព្វផ្សាយពាណិជ្ជកម្មរបស់សហគ្រាស ក និង សហគ្រាស ខ ជាខ្នាតដ៏ជាក់លាក់មួយសម្រាប់ញែកទ្រព្យសកម្មអរូបី ការញែកចំណេញនៅសល់ត្រូវបានអនុវត្តដូចខាងក្រោម÷

| ចំណាយ | សហគ្រាស ក | សហគ្រាស ខ |
|---|---|---|
| ចំណាយលើការស្រាវជ្រាវ និងអភិវឌ្ឍ/ចំណាយទីផ្សារ | ២០ | ១៥ |
| សរុបចំណាយលើការស្រាវជ្រាវ និងអភិវឌ្ឍ/ចំណាយទីផ្សាររបស់ ក និង ខ | ៣៥ | |
| អត្រាចំណាយ | ៥៧% | ៤៣% |

- ការញែកចំណេញដែលនៅសល់

| | |
|---|---|
| សហគ្រាស ក | = ៥៧% x ១៤០ = ៨០ |
| សហគ្រាស ខ | = ៤៣% x ១៤០ = ៦០ |

- ចំណេញសរុបសម្រាប់ សហគ្រាស ក និង សហគ្រាស ខ

| ចំណេញ | សហគ្រាស ក | សហគ្រាស ខ |
|---|---|---|
| ចំណេញមូលដ្ឋាន | ១៥ | ១៥ |
| ចំណេញនៅសល់ | ៨០ | ៦០ |
| ចំណេញសរុប | ៩៥ | ៧៥ |

- ចំណេញក្រោយនិយ័តកម្មរបស់សហគ្រាស ក និង សហគ្រាស ខ

| **បរិយាយ** | សហគ្រាស ក | សហគ្រាស ខ |
|---|---|---|
| ចំណូលពីការផ្គត់ផ្គង់ | ១០០ | ៣០០ |
| និយ័តកម្មចំណូលតាមគោលការណ៍ជិះហោងដៃ | **៦៥** | - |
| ចំណូលពីការផ្គត់ផ្គង់ក្រោយនិយ័តកម្ម | **១៦៥** | - |
| ការទិញ | (១៥) | (១០០) |
| និយ័តកម្មថ្លៃទិញតាមគោលការណ៍ជិះហោងដៃ | - | **(៦៥)** |
| ថ្លៃទិញក្រោយនិយ័តកម្ម | - | **(១៦៥)** |
| ថ្លៃបំប្លែង | (២០) | (៣៥) |
| ចំណូលដុលក្រោយដកថ្លៃដើមក្រោយនិយ័តកម្ម | **១៣០** | **១០០** |
| ចំណាយលើការស្រាវជ្រាវ និងអភិវឌ្ឍ | (២០) | (១៥) |
| ចំណាយប្រតិបត្តិការផ្សេងៗ | (១៥) | (១០) |
| ចំណេញក្រោយនិយ័តកម្ម | **៩៥** | **៧៥** |

២- របៀបវិភាគលើការរួមចំណែក តម្រូវឱ្យមានការញែកចំណេញសុរបរបស់បុគ្គលទាក់ទិនដោយផ្អែកលើតម្លៃឬកម្រិតនៃការចូលរួមបំពេញមុខងារដោយបុគ្គលទាក់ទិននីមួយៗនៅក្នុងប្រតិបត្តិការមានការរៀបចំ។ ការវិភាគត្រូវផ្ដោតសំខាន់លើភាពខុសគ្នានៃចរិតនិងកម្រិតនៃការចូលរួមរបស់ភាគីនីមួយៗ ដូចជាការផ្ដល់សេវាកម្មការវិនិយោគមូលធនជាដើម ហើយរៀបចំជាអត្រាសមាមាត្រនៃការរួមចំណែកដោយផ្អែកតាមតម្លៃឬកម្រិតនៃការចូលរួមបំពេញមុខងារនិងទិន្នន័យដែលបានមកពីប្រតិបត្តិការគ្មានការរៀបចំ។

**ប្រការ ១៥.- ចំណុចសំខាន់ៗដែលត្រូវពិចារណាចំពោះទ្រព្យអរូបី**

១- ទ្រព្យអរូបី សំដៅដល់ទ្រព្យទាំងឡាយណាដែលមិនមែនជាទ្រព្យរូបវន្តឬទ្រព្យហិរញ្ញវត្ថុ។ ទ្រព្យអរូបីអាចត្រូវបានកាន់កាប់ឬគ្រប់គ្រងសម្រាប់ប្រើប្រាស់ក្នុងសកម្មភាពអាជីវកម្ម។ បុគ្គលដែលមានលទ្ធភាពជាម្ចាស់ ឬអ្នកគ្រប់គ្រងឬអ្នកដែលប្រើប្រាស់ ឬទទួលសិទ្ធិប្រើប្រាស់នូវទ្រព្យអរូបីនោះ នឹងត្រូវទទួលបានមកវិញនូវផលប្រយោជន៍សេដ្ឋកិច្ចក្នុងលក្ខខណ្ឌដែលប្រតិបត្តិការត្រូវបានធ្វើឡើងរវាងសហគ្រាសឯករាជ្យក្នុងកាលៈទេសៈដែលអាចប្រៀបធៀបបាន។

២- ទ្រព្យអរូបីជាអាទិ៍មាន ប្រកាសនីយបត្រតក្កកម្ម ចំណេះដឹងឬចំណេះធ្វើ ពាណិជ្ជសញ្ញា ពាណិជ្ជនាម សិទ្ធិចម្លង រចនាបទដែលបានចុះបញ្ជី សិទ្ធិប្រើប្រាស់អាជ្ញាប័ណ្ណ ស្នាដៃអក្សរសាស្ត្រនិងសិល្បៈ និងទ្រព្យប្រហាក់ប្រហែលផ្សេងទៀតដែលមានតម្លៃជាកម្មសិទ្ធិបញ្ញាឬអរូបី។ ដោយមិនកំណត់ត្រឹមតែទ្រព្យដូចតទៅនេះ ពាណិជ្ជសញ្ញា និងពាណិជ្ជនាមត្រូវបានកំណត់ថាជាទ្រព្យអរូបីទីផ្សារ។ ដោយឡែក ប្រកាសនីយបត្រតក្កកម្មដែលជានិច្ចកាលកើតឡើងតាមរយៈការស្រាវជ្រាវនិងអភិវឌ្ឍដែលមានហានិភ័យ និងចំណាយខ្ពស់ ត្រូវបានកំណត់ថាជាទ្រព្យអរូបីពាណិជ្ជកម្ម។ ការផ្ទេរទ្រព្យអរូបីរវាងបុគ្គលទាក់ទិនអាចត្រូវបានធ្វើឡើងតាមរូបភាពដូចខាងក្រោម÷

ក. ការលក់ផ្ដាច់ ឬការផ្ទេរ សម្រាប់ការដោះដូរជាប្រាក់ឬជាវត្ថុ ឬជាការដាក់ដើមទុន។

ខ. ការជួល ឬផ្ដល់អាជ្ញាប័ណ្ណក្នុងករណីដែលសួយសារត្រូវបង់ឱ្យម្ចាស់ទ្រព្យអរូបី។

៣- ជាទូទៅ ទ្រព្យអរូបីមានចរិតជាទ្រព្យឯកលក្ខណៈដែលតម្រូវឱ្យមានការយកចិត្តទុកដាក់ពិនិត្យឱ្យច្បាស់លាស់លើលក្ខខណ្ឌនានានៃកិច្ចព្រមព្រៀងនីមួយៗ។ លក្ខខណ្ឌដែលតែងតែត្រូវបានកំណត់ក្នុងការផ្ទេរទ្រព្យអរូបីរវាងម្ចាស់និងអ្នកទទួល ជាអាទិ៍មាន÷

ក. ជាការលក់ផ្ដាច់ ឬការផ្ដល់អាជ្ញាប័ណ្ណសម្រាប់ទទួលបានការទូទាត់សួយសារ

ខ. តម្លៃទ្រព្យអរូបី ដែលអាចត្រូវបានរួមបញ្ចូលនូវតម្លៃគបស្នងនៃការប្រើប្រាស់ទ្រព្យអរូបី ដូចជាសួយសារ ឬសេវាបច្ចេកទេស

គ. មូលដ្ឋាននៃការទូទាត់សួយសារ

ឃ. ចំណាយទីផ្សារទាក់ទិននឹងទ្រព្យអរូបីទីផ្សារ ប្រសិនបើអ្នកធ្វើសកម្មភាពទីផ្សារមិនមែនជាម្ចាស់ផ្លូវច្បាប់លើទ្រព្យអរូបី។

៤- ការវិភាគលើភាពដែលអាចធៀបបានក្រោមគោលការណ៍ជំហោងដែសម្រាប់ទ្រព្យអរូបី អនុវត្តដូចគ្នាទៅនឹងទ្រព្យរូបីដែរ ដោយផ្ដោតទៅលើចំណុចដូចខាងក្រោម÷

ក. ផលប្រយោជន៍ដែលរំពឹងថានឹងទទួលបានពីទ្រព្យអរូបីទាំងក្នុងប្រតិបត្តិការមានការរៀបចំ និងប្រតិបត្តិការគ្មានការរៀបចំ។

ខ. ប្រកាសនីយប័ត្រតក្កកម្ម÷ ចរិត រយៈពេល ច្បាប់ទាក់ទងនឹងប្រកាសនីយប័ត្រតក្កកម្មនៃសាមីប្រទេស និងតម្លៃដែលភ្ជាប់ជាមួយប្រកាសនីយប័ត្រតក្កកម្មនោះ

គ. ទ្រព្យអរូបីទីផ្សារ÷ តម្លៃបន្ថែមលើទ្រព្យដោយគិតពីកិត្តិនាម ទីតាំងភូមិសាស្ត្រ ចំណែកទីផ្សារ ទំហំនៃការផ្គត់ផ្គង់។ល។

ឃ. ចំនួនទឹកប្រាក់ ចរិត និង ចំណាយដើម្បីអភិវឌ្ឍ ឬរក្សានូវទ្រព្យអរូបី ដើម្បីកំណត់នូវតម្លៃរួមចំណែកនៃភាគីនីមួយៗ។

**ប្រការ ១៦.- វិធីកំណត់ភាពជាម្ចាស់នៃទ្រព្យអរូបីក្នុងចំណោមបុគ្គលទាក់ទិន**

ក្នុងករណីទ្រព្យអរូបីត្រូវបានគ្រប់គ្រងឬប្រើប្រាស់ក្នុងចំណោមបុគ្គលទាក់ទិន ការកំណត់ភាពជាម្ចាស់នៃទ្រព្យអរូបី តម្រូវឱ្យអនុវត្តជំហានទាំងឡាយដូចតទៅ÷

ក. រកឱ្យឃើញនូវទ្រព្យអរូបីដែលត្រូវបានគ្រប់គ្រងឬប្រើប្រាស់នៅក្នុងប្រតិបត្តិការ និងកំណត់ហានិភ័យផ្នែកសេដ្ឋកិច្ច (Economically Significant Risks) ពាក់ព័ន្ធនឹងទ្រព្យអរូបីដូចខាងក្រោម÷

- ការអភិវឌ្ឍ (Development)
- ការកែលម្អ (Enhancement)
- ការថែទាំ (Maintenance)
- ការការពារ (Protection) និង
- ការទទួលបានផលប្រយោជន៍ពីទ្រព្យអរូបី (Exploitation)។

ខ. ពិនិត្យកិច្ចព្រមព្រៀងដោយផ្តោតសំខាន់លើការកំណត់កម្មសិទ្ធិស្របច្បាប់នៃទ្រព្យអរូបីដោយផ្អែកលើលក្ខខណ្ឌដែលមានចែងក្នុងកិច្ចព្រមព្រៀងរួមមាន លក្ខខណ្ឌចុះបញ្ជី លក្ខខណ្ឌនៃការផ្តល់អាជ្ញាប័ណ្ណ និងឯកសារគតិយុត្តផ្សេងៗដែលបញ្ជាក់ពីកម្មសិទ្ធិស្របច្បាប់របស់ទ្រព្យ ព្រមទាំងសិទ្ធិនិងកាតព្វកិច្ចនានារួមបញ្ចូលទាំងការគ្រោងទុកនូវហានិភ័យសំខាន់ៗក្នុងចំណោមបុគ្គលទាក់ទិន។

គ. ធ្វើការវិភាគលើ ការអនុវត្តមុខងារ ការប្រើប្រាស់ទ្រព្យសកម្ម និងការគ្រប់គ្រងហានិភ័យ របស់ភាគីនីមួយៗដែលពាក់ព័ន្ធនឹងការអភិវឌ្ឍ ការកែលម្អ ការថែទាំ ការការពារ និងការទទួលបានផលប្រយោជន៍ពីទ្រព្យអរូបី ជាពិសេសរកឱ្យឃើញភាគីដែលទទួលបន្ទុកគ្រប់គ្រងមុខងារខាងក្រៅ និងគ្រប់គ្រងហានិភ័យសេដ្ឋកិច្ចសំខាន់ៗ។

ឃ. ពិនិត្យអំពីសង្គតិភាពរវាងលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនិងការអនុវត្តរបស់ភាគីនីមួយៗ និងកំណត់ឱ្យឃើញថាភាគីណាមួយជាភាគីដែលប្រឈមនឹងហានិភ័យសេដ្ឋកិច្ចសំខាន់ៗ ដូចដែលមានចែងក្នុងជំហាន (ខ) នៃប្រការនេះ ជាភាគីគ្រប់គ្រងហានិភ័យនិងមានលទ្ធភាពហិរញ្ញវត្ថុដើម្បីប្រឈមនឹងហានិភ័យដែលពាក់ព័ន្ធនឹងការអភិវឌ្ឍ ការកែលម្អ ការថែទាំ ការការពារ និងការទទួលបានផលប្រយោជន៍ពីទ្រព្យអរូបី។

ង. បង្ហាញថាប្រតិបត្តិការមានការរៀបចំដែលបានកើតឡើងជាក់ស្តែងមានការពាក់ព័ន្ធនឹងការអភិវឌ្ឍ ការកែលម្អ ការថែទាំ ការការពារ និងការទទួលបានផលប្រយោជន៍ពីទ្រព្យអរូបី ដោយផ្តោតលើកម្មសិទ្ធិស្របច្បាប់នៃទ្រព្យអរូបីនោះ ព្រមទាំងកិច្ចសន្យាផ្សេងៗទៀតដែលពាក់ព័ន្ធនឹងការចុះបញ្ជីទ្រព្យអរូបី កិច្ចព្រមព្រៀងនិងការអនុវត្ត រួមបញ្ចូលទាំងមុខងារ ទ្រព្យសកម្ម និងហានិភ័យ ដែលភាគីនីមួយៗបានចូលរួម។

ច. កំណត់នូវថ្លៃជំហោងដែលសម្រាប់ប្រតិបត្តិការទាំងនេះដើម្បីឱ្យមានសង្គតិភាពទៅនឹងមុខងារ ទ្រព្យសកម្ម និងហានិភ័យ ដែលភាគីនីមួយៗបានចូលរួម។

ចំពោះការផ្ទេរថ្លៃដែលពាក់ព័ន្ធនឹងទ្រព្យអរូបី ត្រូវកំណត់ឱ្យឃើញថាសហគ្រាសទាំងឡាយណាមានសិទ្ធិទទួលបាននូវការបែងចែកចំណេញពីផលប្រយោជន៍នៃទ្រព្យអរូបីដែលក្រុមសហសគ្រាសនោះទទួលបាន។ ការបែងចែកចំណេញខាងលើ ត្រូវអនុវត្តទៅតាមគោលការណ៍ជំហោងដៃ និងផ្អែកលើបន្ទុកចំណាយ ការវិនិយោគ និងបន្ទុកផ្សេងៗទៀតពាក់ព័ន្ធការអភិវឌ្ឍ ការកែលម្អ ការថែទាំ ការការពារ និងការទទួលបានផលប្រយោជន៍ពីទ្រព្យអរូបី។

**ប្រការ ១៧.- សេវាក្នុងចំណោមសហគ្រាសសម្ព័ន្ធញាតិ** (Intra-group services)

ក្នុងចំណោមសហគ្រាសសម្ព័ន្ធញាតិ តែងតែមានការរៀបចំយ៉ាងទូលំទូលាយនូវសេវាដើម្បីផ្តត់ផ្គង់ឱ្យគ្នាទៅវិញទៅមក ជាពិសេសសេវារដ្ឋបាល សេវាបច្ចេកទេស សេវាហិរញ្ញវត្ថុ និងសេវាពាណិជ្ជកម្ម ដែលអាចរួមបញ្ចូលទាំងការគ្រប់គ្រង ការសម្របសម្រួល និងមុខងារត្រួតពិនិត្យសម្រាប់សម្ព័ន្ធញាតិទាំងមូល។ ចំណាយសម្រាប់ការផ្គត់ផ្គង់សេវាទាំងនេះ ជាបន្ទុករបស់សហគ្រាសមេឬសហគ្រាសផ្គត់ផ្គង់សេវាណាមួយនៅក្នុងសហគ្រាសសម្ព័ន្ធញាតិ ហើយដែលក្រោយមកសហគ្រាសទាក់ទិនទាំងនាត្រូវបានរៀបចំឱ្យធ្វើការទូទាត់សងវិញ។

ចំនុចសំខាន់ ២ ដែលត្រូវពិនិត្យលើសេវាក្នុងចំណោមសហគ្រាសសម្ព័ន្ធញាតិ គឺសេវាត្រូវបានផ្គត់ផ្គង់យ៉ាងពិតប្រាកដ ហើយថ្លៃសេវាដែលបានផ្គត់ផ្គង់នោះ គឺជាថ្លៃជំហោងដៃ។

១. ការពិនិត្យភាពពិតប្រាកដនៃការផ្គត់ផ្គង់សេវា

កត្តាកំណត់អំពីភាពពិតប្រាកដនៃការផ្គត់ផ្គង់សេវាមានដូចខាងក្រោម÷

ក. ត្រូវវិភាគអំពីតម្លៃសេដ្ឋកិច្ចនិងពាណិជ្ជកម្ម និងតម្រូវការចាំបាច់នៃសេវាដែលបានផ្គត់ផ្គង់ក្នុងចំណោមសហគ្រាសសម្ព័ន្ធញាតិ ដោយធ្វើការប្រៀបធៀបទៅនឹងសហគ្រាសឯករាជ្យដែលស្ថិតក្នុងកាលៈទេសៈ ប្រហាក់ប្រហែលគ្នា។

ខ. ពិនិត្យនិងពិចារណាដើម្បីកាត់ចេញនូវចំណាយផ្សេងៗដែលកើតឡើងនៅក្នុងសហគ្រាសសម្ព័ន្ធញាតិចំពោះការបំពេញមុខងាររបស់ម្ចាស់ភាគហ៊ុន ដែលមិនត្រូវបានចាត់ទុកជាសេវានោះទេ។ មុខងារទាំងនេះរួមបញ្ចូលទាំងសកម្មភាពដែលពាក់ព័ន្ធជាមួយនឹងរចនាសម្ព័ន្ធយុត្តាធិការរបស់ក្រុមហ៊ុនមេ ដូចជាកិច្ចប្រជុំម្ចាស់ភាគហ៊ុន ការបោះផ្សាយភាគហ៊ុនរបស់ក្រុមហ៊ុនមេ ចំណាយសេវាគ្រប់គ្រងដល់ក្រុមប្រឹក្សាភិបាល ចំណាយទាក់ទិននឹងការរៀបចំរបាយការណ៍តាមតម្រូវការរបស់ក្រុមហ៊ុនមេ ចំណាយកៀរគរមូលនិធិដើម្បីទិញភាគហ៊ុនក្រុមហ៊ុនដទៃទៀត ។ល។

គ. ពិនិត្យនិងពិចារណាដើម្បីកាត់ចេញនូវចំណាយលើសេវាក្នុងចំណោមសហគ្រាសសម្ព័ន្ធញាតិ ចំពោះសេវាណាដែលត្រួតគ្នាជាមួយសេវាដែលសមាជិកមួយទៀតក្នុងក្រុមបាននឹងកំពុងបំពេញដោយខ្លួនឯង ឬដោយតតិយជន។

ឃ. ពិនិត្យនិងពិចារណាដើម្បីកាត់ចេញនូវចំណាយផ្សេងៗលើសកម្មភាព ឬសេវាដែលបំពេញដោយសមាជិកផ្សេងទៀតនៃសហគ្រាសសម្ព័ន្ធញាតិ ដែលផ្តល់នូវអត្ថប្រយោជន៍បន្ទាប់បន្សំ។ ឧទាហរណ៍÷ សហគ្រាសមិនត្រូវចាត់ទុកជាចំណាយសេវាក្នុងចំណោមសហគ្រាសសម្ព័ន្ធញាតិទេ ចំពោះអត្ថប្រយោជន៍ដែលទទួលបានក្នុងភាពជាផ្នែកមួយនៃសហគ្រាសសម្ព័ន្ធញាតិ ដែលអាចមានលទ្ធភាពទិញទំនិញឬសេវាក្នុងតម្លៃទាប ដោយសារឥទ្ធិពលនិងកេរ្តិ៍ឈ្មោះរបស់សហគ្រាសសម្ព័ន្ធញាតិនោះ។

២. ការពិនិត្យលើថ្លៃសេវាដែលបានផ្គត់ផ្គង់

ក្រោមគោលការណ៍ជិះហោងដៃ ការពិនិត្យថ្លៃសេវាដែលបានផ្គត់ផ្គង់ តម្រូវឱ្យមានការវិភាគមុខងាររបស់សមាជិកសហគ្រាសសម្ព័ន្ធញាតិ ដើម្បីកំណត់នូវទំនាក់ទំនងរវាងសេវា និងសកម្មភាពដែលពាក់ព័ន្ធរបស់សមាជិក។ ការកំណត់ថ្លៃជិះហោងដៃសម្រាប់សេវាក្នុងចំណោមសហគ្រាសសម្ព័ន្ធញាតិ ត្រូវអនុលោមតាមលក្ខខណ្ឌនានាដែលមានចែងក្នុងប្រការ ៧ ដល់ប្រការ ១៤ នៃប្រកាសនេះ។

ក្នុងករណីប្រើប្រាស់វិធីផ្អែកលើថ្លៃដើម ត្រូវពិនិត្យនិងធ្វើនិយ័តកម្មលើថ្លៃដើមសេវារបស់អ្នកផ្គត់ផ្គង់ ដោយធ្វើការប្រៀបធៀបរវាងប្រតិបត្តិការមានការរៀបចំនិងប្រតិបត្តិការគ្មានការរៀបចំ។

សេវាអាចត្រូវបានគិតថ្លៃដោយផ្ទាល់ ឬដោយប្រយោល។ ការគិតថ្លៃដោយផ្ទាល់គឺថ្លៃសេវាត្រូវបានកំណត់រួចរាល់ចំពោះសេវាជាក់លាក់។ ការគិតថ្លៃដោយប្រយោលគឺសេវាត្រូវបានផ្គត់ផ្គង់ដោយសហគ្រាសមេ ឬមជ្ឈមណ្ឌលផ្គត់ផ្គង់សេវា ហើយធ្វើការបែងចែកចំណាយសេវាទាំងនោះទៅឱ្យសហគ្រាសសម្ព័ន្ធញាតិតាមរយៈការប៉ាន់ស្មានដោយផ្អែកលើមូលដ្ឋាន ផលរបរ ចំនួនបុគ្គលិក ឬបរិក្ខារកុំព្យូទ័រ ។ល។

**ប្រការ ១៨.- ការកាន់កាប់រក្សាទុកឯកសារ** (Documentation)

១- អ្នកជាប់ពន្ធត្រូវចេញវិក័យបត្រលើរាល់ប្រតិបត្តិការអាជីវកម្ម ហើយត្រូវកត់ត្រា កាន់កាប់ រក្សាទុក នូវបញ្ជីកាគណនេយ្យ លិខិតយុត្តិការ និងឯកសារហិរញ្ញវត្ថុផ្សេងៗដូចដែលបទប្បញ្ញត្តិស្តីពីពន្ធដារបានកំណត់ និងត្រូវផ្តល់ជូនតាមការតម្រូវរបស់រដ្ឋបាលសារពើពន្ធ។ បញ្ជីកាគណនេយ្យ លិខិតយុត្តិការ និងឯកសារហិរញ្ញវត្ថុខាងលើនេះ ត្រូវរក្សាទុកក្នុងរយៈពេល ១០ ឆ្នាំ គិតចាប់ពីដំណាច់ឆ្នាំជាប់ពន្ធ។

២- សម្រាប់គោលដៅនៃការផ្ទេរថ្លៃ ការកត់ត្រា ការកាន់កាប់ និងការរក្សាទុកបញ្ជីកាគណនេយ្យ លិខិតយុត្តិការ និងឯកសារហិរញ្ញវត្ថុផ្សេងៗទាំងនេះ នឹងផ្តល់គុណប្រយោជន៍ដល់អ្នកជាប់ពន្ធ ដែលអាចកាត់បន្ថយហានិភ័យនៃការធ្វើសវនកម្មពន្ធដារ និងការធ្វើនិយ័តកម្មរបស់រដ្ឋបាលសារពើពន្ធក្រោមគោលការណ៍ជិះហោងដៃ។ ដោយមិនកម្រិតត្រឹមតែដូចខាងក្រោមនេះ អ្នកជាប់ពន្ធដែលមានប្រតិបត្តិការជាមួយបុគ្គលទាក់ទិនត្រូវមានកាតព្វកិច្ចរៀបចំឱ្យបានស្រេចបាច់នូវព័ត៌មានដូចខាងក្រោម÷

ក. ព័ត៌មានទូទៅរបស់សហគ្រាស និងបុគ្គលទាក់ទិន ជាអាទិ៍មាន÷

- ឯកសារបញ្ជាក់អំពីរចនាសម្ព័ន្ធនិងទំនាក់ទំនងក្នុងចំណោមសហគ្រាសសម្ព័ន្ធញាតិ រួមទាំង រចនាសម្ព័ន្ធនិងចរិតនៃអាជីវកម្មដែលបានធ្វើឡើងដោយសហគ្រាសនីមួយៗ
- ឯកសារនិងរបាយការណ៍ស្តីពីយុទ្ធសាស្ត្រអភិវឌ្ឍន៍និងអាជីវកម្ម គម្រោងនានាពាក់ព័ន្ធនឹងអភិវឌ្ឍន៍និងអាជីវកម្ម ផែនការវិនិយោគ ប្រតិបត្តិការអាជីវកម្មនិងផលិតកម្ម និងបញ្ញត្តិនិងនីតិវិធីពាក់ព័ន្ធការគ្រប់គ្រងនិងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

ខ. ព័ត៌មានស្តីពីប្រតិបត្តិការរបស់សហគ្រាស÷

- កិច្ចសន្យាបំពេញនិងឯកសារពិពណ៌នាអំពីប្រតិបត្តិការ រួមបញ្ចូលទាំង ព័ត៌មានអំពីភាគីពាក់ព័ន្ធ និងលក្ខខណ្ឌនិងបែបបទនៃការផ្គត់ផ្គង់ ការដឹកជញ្ជូន ការទូទាត់។ល។
- ឯកសារពិពណ៌នាអំពីចរិតលក្ខណៈ និងលក្ខណៈពិសេសរបស់ផលិតផល បញ្ជីលម្អិតអំពីការចំណាយសម្រាប់ផលិតផលក្នុងមួយឯកតា ថ្លៃលក់ផលិតផល បរិមាណសរុបនៃផលិតផលដែលបានផលិតនិងផ្គត់ផ្គង់ក្នុងឆ្នាំជាប់ពន្ធនីមួយៗ
- ព័ត៌មាន ឯកសារស្តីអំពីការចរចា ការចុះហត្ថលេខា ការអនុវត្ត និងការបញ្ចប់កិច្ចសន្យាពាក់ព័ន្ធនឹងប្រតិបត្តិការ
- ព័ត៌មាន និងឯកសារពាក់ព័ន្ធនឹងស្ថានភាពសេដ្ឋកិច្ចទីផ្សារក្នុងអំឡុងពេលដែលប្រតិបត្តិការកើតឡើង ដែលអាចប៉ះពាល់ដល់វិធីផ្ទេរថ្លៃដែលបានប្រើប្រាស់។

គ. ព័ត៌មានអំពីវិធីផ្ទេរថ្លៃ

- គោលនយោបាយថ្លៃ លទ្ធភាពចំណេញពីផលិតផល ព័ត៌មានទីផ្សារពាក់ព័ន្ធនឹងការបែងចែកចំណេញក្នុងចំណោមសហគ្រាសសម្ព័ន្ធញាតិ
- ឯកសារគាំទ្រដល់ការជ្រើសរើសវិធីផ្ទេរថ្លៃ
- ក្នុងករណីមានជម្រើសវិធីផ្ទេរថ្លៃច្រើន ត្រូវមានឯកសារដែលបញ្ជាក់លម្អិតអំពីហេតុផលនៃការជ្រើសរើសវិធីណាមួយ និងហេតុផលនៃការមិនជ្រើសរើសវិធីដទៃទៀត
- ឯកសារជាភស្តុតាងបញ្ជាក់អំពីមូលដ្ឋាននិងជំហរក្នុងការចរចាររវាងអ្នកជាប់ពន្ធ និងសហគ្រាសសម្ព័ន្ធញាតិទាក់ទិនទៅនឹងប្រតិបត្តិការអាជីវកម្ម
- ឯកសារផ្សេងទៀតដែលទាក់ទិននឹងការផ្ទេរថ្លៃ។

៣- អ្នកជាប់ពន្ធត្រូវបានតម្រូវឱ្យបំពេញក្នុងលិខិតប្រកាសពន្ធលើចំណូលប្រចាំឆ្នាំ អំពីព័ត៌មានមួយចំនួនពាក់ព័ន្ធនឹងប្រតិបត្តិការក្នុងចំណោមបុគ្គលទាក់ទិន និងតម្រូវឱ្យផ្តល់ឯកសារទាំងឡាយដូចមានចែងក្នុងកថាខណ្ឌ ២ នៃប្រការនេះ ទៅតាមការចាំបាច់របស់រដ្ឋបាលសារពើពន្ធ។

**ប្រការ ១៩.- ទោសទណ្ឌ**

ដោយមិនទាន់គិតពីទោសទណ្ឌដទៃទៀត ការខកខានមិនបានអនុវត្តកាតព្វកិច្ចដូចមានចែងក្នុងប្រការ ១៨ នៃប្រកាសនេះ អ្នកជាប់ពន្ធត្រូវបានដកហូតមកវិញនូវវិញ្ញាបនបត្រអនុលោមភាពសារពើពន្ធ ឬត្រូវវាយតម្លៃ

អនុលោមភាពសារពើពន្ធឡើងវិញ និងត្រូវទទួលរងនូវទោសទណ្ឌដូចមានចែងក្នុងមាត្រា ១៣៣ នៃច្បាប់ស្តីពីសារពើពន្ធ។ ក្នុងករណីចាំបាច់ រដ្ឋបាលសារពើពន្ធអាចប្តឹងចោទប្រកាន់និងទាមទារដាក់ទោសចំពោះបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារដូចមានចែងក្នុងមាត្រា ១៣៤ ដល់ មាត្រា ១៣៨ នៃច្បាប់ស្តីពីសារពើពន្ធ។

**ប្រការ ២០.- និរាករណ៍**

បទប្បញ្ញត្តិទាំងឡាយណាដែលទាក់ទិននឹង វិធាននិងនីតិវិធីសម្រាប់បែងចែកចំណូលនិងចំណាយក្នុងចំណោមបុគ្គលទាក់ទិន ដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ២១.- ការអនុវត្ត**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អាគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១០ ខែ៧ ឆ្នាំ ២០១៧

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ ២១ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ